**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

086 812 268

សាលាដំបូងខេត្តសៀមរាប

**សាលក្រមព្រហ្មទណ្ឌ**
**លេខ ៧៧(ឃ)/៧៦៩**
ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣
សំណុំរឿងព្រហ្មទណ្ឌលេខ ៨០៤
ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ ៥២៦
ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាប។

-កាលបរិច្ឆេទបើកសវនាការថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ០២:៣០នាទីរសៀល។

-កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង០៤:០០នាទីរសៀល។

### ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាអនុប្រធាន និងជាចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៨០៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ ដែលមានជនជាប់ចោទមានអត្តសញ្ញាណដូចខាងក្រោម៖

១. ឈ្មោះ [redacted] ផល្លា ភេទប្រុស អាយុ៥៤ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៧ មុខរបរមន្ត្រីចូលនិវត្តន៍ ឪពុកឈ្មោះ [redacted] ឈួន (ស) ម្តាយឈ្មោះ [redacted] គីន (រ) ប្រពន្ធឈ្មោះ [redacted] រ៉ាវី មានកូន៣នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ (ក្រៅឃុំ)

២. ឈ្មោះ [redacted] គឹមឃ្លេវ ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ននៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៥ មុខរបរកសិករ ឪពុកឈ្មោះ [redacted] ហាក់ (រ) ម្តាយឈ្មោះ [redacted] អឿន (រ) ប្រពន្ធឈ្មោះ [redacted] គឹមយឿន មានកូន៣នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទ “ប្រឆាំងនឹងការអនុវត្តការងារសាធារណៈ ហិង្សាដោយចេតនា និងគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ” ប្រព្រឹត្តនៅចំណុចភូមិអញ្ចាញ សង្កាត់



Scanned with CamScanner

នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៥០៦ មាត្រា២១៧ និងមាត្រា២៣៤ នៃក្រមព្រហ្មទណ្ឌ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា។

- ដោយមានលោក [redacted] ជាសហមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

- ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] គឹមហួរ និងឈ្មោះ [redacted] ផល្លា។

- ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] គឹមហួរ។

- ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] គឹមហួរ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ មេធាវីតំណាងនៃក្រុមមេធាវីអាជ្ញាធរជាតិអប្សរា បានចូលមកអយ្យការអមសាលាដំបូងខេត្តសៀមរាប ដាក់ពាក្យបណ្តឹងលើជនសង្ស័យឈ្មោះ [redacted] ផល្លា ភេទប្រុស អាយុ៥៤ឆ្នាំ ឈ្មោះ [redacted] គឹមហួរ ភេទប្រុស អាយុ៤៧ឆ្នាំ ឈ្មោះ ហ៊ឹប ភេទប្រុស ឈ្មោះ ប៊ុន ភេទប្រុស ឈ្មោះ យ៉ុង ភេទប្រុស និងបក្សពួក ពីបទ "ប្រឆាំងនឹងការអនុវត្តការងារសាធារណៈ ហិង្សាដោយចេតនា និងគំរាមគំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ"។ រឿងហេតុដំបូង កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការនៃអាជ្ញាធរជាតិអប្សរា បានចុះអនុវត្តវិធានការរដ្ឋបាលរុះរើសំណង់ខុសច្បាប់មួយចំនួននៅក្នុងតំបន់២នៃរមណីយដ្ឋានអង្គរស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ នៅពេលចុះរុះរើ មានប្រជាពលរដ្ឋជាច្រើនក្នុងនោះមានឈ្មោះ [redacted] ផល្លា ឈ្មោះ [redacted] គឹមហួរ ឈ្មោះ [redacted] ឈ្មោះ ប៊ុន ឈ្មោះ យ៉ុង និងបក្សពួក ប្រដាប់ដោយញញួរ ពូថៅ ដំបង និងកាំបិតខ្មែរ កាន់នៅនឹងដៃអ្នកខ្លះទុកនៅនឹងម៉ូតូ ហើយអ្នកខ្លះទៀតថតជាវីដេអូ បានចេញមកធ្វើសកម្មភាពរារាំងគំរាមថានឹងប្រើអំពើហិង្សា ហើយយកប្រេងសាំងចាក់លើរថយន្តរបស់ក្រុមការងារផ្នែកខាងក្រោយ និងកង់រថយន្ត ហើយគំរាមថាបើក្រុមការងារហ៊ានរុះរើនឹងដុតចោល។ ទើបក្រុមការងារពុំអាចធ្វើការរុះរើបាន ហើយក៏សម្រេចដកកម្លាំងត្រលប់ទៅវិញ។ ក្នុងពេលក្រុមការងារធ្វើដំណើរត្រលប់ទៅវិញ ក្រុមជនសង្ស័យខាងលើបានជិះម៉ូតូដេញតាម និងកាត់រថយន្តក្រុមការងារឱ្យឈប់ ហើយធ្វើសកម្មភាពយកដុំថ្មគប់ត្រូវចំដងខ្លួនរបស់ឈ្មោះ [redacted] ស៊ីធុន និងហក់ទៅវាយលើឈ្មោះ [redacted] យ៉ង់ ចំនួនពីរដៃ ឈ្មោះ សុខ ចំនួនពីរដៃត្រូវចំមុខ ឈ្មោះ [redacted] ស្រស់ ចំនួនបីដៃ និងឈ្មោះ [redacted] វន ចំនួនបីដៃ ត្រូវចំក្បាលផ្នែកខាងក្រោយ។ ក្រោយពីវាយរួចក្រុមជនសង្ស័យបានស្រែកគំរាមទៅកាន់ក្រុមការងារថា "ចេញទៅហើយ ហាមមកវិញជារៀងរហូត មិនថាអ្នកជិះល្បាតរថយន្ត ម៉ូតូ ឬ កង់ ឱ្យតែឃើញចូលក្នុងភូមិអញ្ចាញ នឹងវាយកាប់សម្លាប់ ដុតឡានម៉ូតូកង់មិនឱ្យចេញទៅវិញបានទេ ប្រាប់ឱ្យហើយបើចង់សុខខ្លួនកុំថាមិនបានប្រាប់"។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៩២ អយក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។



Scanned with CamScanner

- បានឃើញ ដីកាដំណោះស្រាយលេខ ២៥០៤ ពស.ព្រស/ជ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៥៤៣ ពស.ព្រជ(ក) ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## នាពេលសវនាការ

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់
- ក្រោយពីបានស្តាប់ការបំភ្លឺរបស់សាក្សី
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹង
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពារសិទ្ធឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល និងពិនិត្យភស្តុតាងនាពេលសវនាការឃើញថា៖

(១)- ឆ្លងតាមកិច្ចពិភាក្សាដេញដោលនាពេលសវនាការបញ្ជាក់ឲ្យឃើញថា មានអង្គហេតុនៃអំពើ "ប្រឆាំងនឹងការអនុវត្តការងារសាធារណៈ ហិង្សាដោយចេតនា និងគំរាមគំហែងថានឹងសម្លាប់ដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ" ប្រព្រឹត្តនៅចំណុចភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ មែន។

(២)- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផល្លា បានឆ្លើយនៅគ្រប់ដំណាក់កាលមានភាពប្រហាក់ប្រហែលគ្នាថា៖ ខ្លួនសុំរក្សាចម្លើយដែលបានឆ្លើយនៅចំពោះមុខតំណាងអយ្យការទុកនៅដដែល។ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ខ្លួននៅផ្ទះរបស់មិត្តភក្តិដែលជួលដើម្បីចិញ្ចឹមមាន់ស្ថិតនៅក្នុងភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ហើយនៅពេលមានរឿងកើតហេតុប្រហែលម៉ោង១២ ថ្ងៃត្រង់ ខ្លួនបានទៅលេងផ្ទះរបស់ឈ្មោះ [redacted] សេរ ដើម្បីទៅលេងគាត់ដែលស្ថិតនៅចម្ងាយប្រហែល៧០០ម៉ែត្រពីកន្លែងកើតហេតុ។ ពេលនោះឈ្មោះ [redacted] សេរ បានបបួលខ្លួនទៅមើលគេឈ្លោះគ្នានៅកន្លែងកើតហេតុ ហើយពេលដែលខ្លួនចុះទៅដល់កន្លែងកើតហេតុគេបានសម្របសម្រួលគ្នា និងបំបែកគ្នាអស់ហើយ។ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ព្រោះខ្លួនមិនបានចូលរួមនៅក្នុងហេតុការណ៍នោះដែរ ហើយក៏មិនបានជួបភាគីអាជ្ញាធរជាតិអប្សរាដែរ។ ពេលដែលខ្លួនទៅដល់កន្លែងកើតហេតុគឺគេបំបែកគ្នារួចអស់ហើយ [redacted]ដោយខាងអាជ្ញាធរជាតិអប្សរា ពួកគាត់បានចាកចេញទៅបាត់ហើយ ខ្លួនក៏មិនបានស្រែកគម្រាមទៅកាន់អ្នកណាដែរ។ ចាប់ពីពេលនេះតទៅ ខ្លួននឹងរុះរើរោង និងទ្រព្យសម្បត្តិរបស់ខ្លួនចេញពីដីស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ក្នុងអំឡុងពេល០១ខែ គិតចាប់ពីថ្ងៃនេះ។ នៅចំពោះមុខសវនាការជនជាប់ចោទឆ្លើយថា៖ ខ្លួនចាំអង្គហេតុបានថា ព្រឹកថ្ងៃទី២២ ខ្លួននៅបាត់ដំបង។ លុះពេលថ្ងៃប្រហែលម៉ោងមួយឬពីរថ្ងៃដដែរ គេប្រាប់ថាមានបញ្ហារឿងអប្សរាចុះរុះរើផ្ទះប្រជាពលរដ្ឋ។ ខ្លួនមានរោងមាន់តែមួយទេ។ ខ្លួន



Scanned with CamScanner

ជិះក្រោយប្អូនទៅមើលគេចំពេលគេចប់រឿងរួចហើយ។ ពេលខ្លួនទៅដល់គេបែកគ្នាអស់ហើយ មានអ្នកភូមិប្រហែល ជាប្អូនរយនាក់។ ទ្រុងមាន់ខ្លួនធ្វើលើដីរបស់មិត្តភក្តិ ខ្លួនមិនយល់ថាហេតុអ្វីបានជាគេប្តឹងខ្លួន ខ្លួនមានសាក្សីឈ្មោះ [redacted] សេរ និងមេភូមិជាសាក្សី។ (តំណាងអយ្យការសួរ) ខ្លួនឃើញអប្សារាគេចេញអស់ហើយ ថ្ងៃនោះខ្លួនស្លៀកសម្លៀកបំពាក់ ស៊ីវិលអង្គុយជិតនោះ។ (មេធាវី [redacted] សួរ) សូមលោកក្រឡាបញ្ជី ចុះកំណត់ហេតុព្រោះនៅចៅក្រមស៊ើបសួរ ជន នេះឆ្លើយថាថ្ងៃកើតហេតុអប្សារាចុះទៅពីរដង។ (មេធាវី [redacted] សួរ) ប្រហែលម៉ោងមួយហូបបាយរួចក៏ដើរទៅផ្ទះ ឈ្មោះ [redacted] សេរ និងលឺថាប្រជាពលរដ្ឋប៉ះគ្នាជាមួយអប្សារា ខ្លួនក៏ជិះម៉ូតូទៅជាមួយឈ្មោះ សេរ ទៅឃើញគេសម្រួល គ្នាបែកគ្នាហើយ។ ចំពោះរូបថតនេះជារូបនៅអង្គុយនៅបង់របស់ឈ្មោះ [redacted] សេរ។ ឈ្មោះ [redacted] សេរ ជាមន្ត្រីប៉ុស្តិ៍ គាត់ ថាមេគាត់បញ្ជាគាត់ឱ្យទៅសម្របសម្រួល ខ្លួនក៏ទៅជាមួយគាត់ទៅ។ ជាទម្លាប់ខ្លួនតែងទៅអង្គុយលេងផ្ទះប្អូន សុទ្ធ សេរ។ ខ្លួនមិនដឹងថាអប្សាររុះរើរបស់អ្នកណានោះទេ ព្រោះខ្ញុំមិនមានដីនៅក្នុងតំបន់នោះទេ។ ខ្លួនសុំសំណូមពរឱ្យ តុលាការរកយុត្តិធម៌ឱ្យខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

(៣)- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **គឹមហ្សេរ** បានឆ្លើយនៅគ្រប់ដំណាក់កាលមានភាព ប្រហាក់ប្រហែលគ្នាថា៖ ខ្លួនសុំបដិសេធចំពោះការចោទប្រកាន់មកលើរូបខ្លួន ព្រោះខ្លួនមិនមានបំណងទៅចូលរួម បាតុកម្មជាមួយគេទេ។ ខ្លួនសុំរក្សាចម្លើយរបស់ខ្លួននៅដំណាក់កាលអយ្យការទុកនៅដដែល។ កាលពីថ្ងៃទី២២ ខែ មិថុនា ឆ្នាំ២០២២ ខ្លួនបានជិះម៉ូតូទៅចំការរបស់ខ្លួនដែលមានចម្ងាយប្រហែល១គីឡូម៉ែត្រ។ ពេលជិះតាមផ្លូវ ខ្លួន បានឃើញមនុស្សជុំគ្នាអ៊ូអរក៏ឈប់ម៉ូតូចូលទៅមើលគេ ហើយក៏ទាញទូរស័ព្ទរបស់ខ្លួនថតវីឌីអូទុកមើល ពេលនោះ ខ្លួនមិនបានចូលរួមជាមួយប្រជាពលរដ្ឋទេ។ ពេលដែលទៅដល់កន្លែងកើតហេតុខ្លួនបានឃើញឡាន ក្រុមការងារ អាជ្ញាធរអប្សរាចំនួន០១គ្រឿង ពេលនោះខ្លួននៅពីក្រោយឡានរបស់អាជ្ញាធរអប្សរាដែរ ប៉ុន្តែខ្លួនមិនបានចូលរួមវាយ និងមិនបានស្រែកគម្រាមអ្នកណាទេ។ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ខាងមន្ត្រីអាជ្ញាធរអប្សរា បានចុះទៅទីតាំង នោះចំនួន០២ដង ដោយទាំងពេលព្រឹក និងពេលរសៀល ហើយខ្លួនបានទៅចូលមើលទាំង២ដង ដោយពេលព្រឹក គឺ ខ្លួនទៅមើលនៅទីកន្លែងដែលអាជ្ញាធរអប្សរាត្រូវចុះរុះរើ ដោយខ្លួនបានយកទូរស័ព្ទថតវីដេអូ ហើយពេលល្ងាចខ្លួន ក៏បានទៅចូលរួមមើលម្តងទៀតនៅតាមផ្លូវ។ ខ្លួនមិនបានចូលរួមប្រើហិង្សា និងមិនបានបញ្ជាអ្នកណាអោយវាយទៅ លើក្រុមការងារអាជ្ញាធរជាតិអប្សរាទេ។ ផ្ទះរបស់ខ្លួនស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្ត សៀមរាប ហើយក៏ស្ថិតនៅក្នុងតំបន់២នៃរមណីដ្ឋានអង្គរផងដែរ។ កន្លងមកផ្ទះរបស់ខ្លួនមិនត្រូវបានក្រុមការងារ អាជ្ញាធរជាតិអប្សរាឱ្យរុះរើទេ។ ប្រសិនបើខាងអាជ្ញាធរជាតិអប្សរាចុះទៅភូមិអញ្ចាញទៀត ខ្លួនមិនចូលរួមទៅ មើលគេទៀតនោះទេ។ នៅចំពោះមុខសវនាការជនជាប់ចោទឆ្លើយថា ៖ ថ្ងៃកើតហេតុ ខ្លួនចៃដន្យជិះម៉ូតូទៅចំការ ខ្លួននៅកន្លែងកើតហេតុកំពុងឈរមើលគេ។ (មេធាវី [redacted] សួរ) ខ្លួនជាកសិករ ខ្លួនជិះម៉ូតូកាត់ឃើញគេអ៊ូអរ ខ្លួនក៏ចូលមើលគេ។ (មេធាវី [redacted] សួរ) ខ្លួនទៅពេលរសៀល មេធាវីសុំគត់សម្គាល់ថា ចម្លើយជនជាប់ចោទ នៅចៅក្រមស៊ើបសួរថាគាត់បានចូលរួមទាំងព្រឹកទាំងល្ងាច។ (មេធាវី [redacted] សួរ) ខ្លួនកាន់ទូរស័ព្ទថតហេតុ ការណ៍ដោយសារខ្លួនជិះចេញពីផ្ទះទៅចំការកន្លែងកើតហេតុនៅចន្លោះចំការ និងផ្ទះរបស់ខ្លួន។ ខ្លួនគ្រាន់តែឈរ មើល កាន់ទូរស័ព្ទថតលេងទេ។ ខ្លួនមិនបានចូលរួមសកម្មភាពផ្សេងៗរបស់ពលរដ្ឋនោះទេ។ លើដំណឹងថាអប្សរាចុះ

ទៅផែករបងប្រជាពលរដ្ឋ។ លំនៅដ្ឋានខ្លួនមិនមានការចុះទៅរុះរើអ្វីទេ។ ខ្លួនមិនមានការប្រើប្រាស់ហិង្សាទៅលើបុគ្គលណាានោះទេ។ ខ្លួនសុំសំណូមពរឱ្យតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។

(៤)-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] សុខ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ខ្លួន និងក្រុមការងារបានទៅចុះរុះរើសំណង់ខុសច្បាប់នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយអនុវត្តតាមបទបញ្ជារបស់ថ្នាក់លើ។ មុនពេលដែលខ្លួនចុះទៅអនុវត្ត គឺបានជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានដើម្បីចូលរួម ហើយពេលទៅដល់ទីកន្លែងកើតហេតុ ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការនៃអាជ្ញាធរជាតិអប្សរា ដែលខ្លួននៅក្នុងនោះដែរបានធ្វើការរុះរើរបង និងរោងរបស់ប្រជាពលរដ្ឋសាងសង់ខុសច្បាប់នៅលើដីទំនេរស្ថិតនៅក្នុងតំបន់២នៃរមណីដ្ឋានអង្គរ ស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ នៅពេលដែលក្រុមការងារខ្លួនកំពុងធ្វើការរុះរើ ស្រាប់តែប្រជាជនដែលរស់នៅក្នុងភូមិអញ្ចាញទាំងអស់នាំគ្នាមករារាំងមិនឱ្យក្រុមការងាររុះរើ ដោយមានកាន់កាំបិត ពូថៅ ដំបង ខ្នែវ មកជាមួយធ្វើឱ្យក្រុមការងាររបស់ខ្លួនផ្អាកការអនុវត្តសិន។ ក្រោយមកខាងមូលដ្ឋានគាត់បានធ្វើការសម្របសម្រួលកុំឱ្យប្រជាពលរដ្ឋប្រើអំពើហិង្សាលើក្រុមការងារ ទើបក្រុមការងារខ្លួនអាចដកកម្លាំងត្រឡប់ទៅនាយកដ្ឋានសណ្តាប់ធ្នាប់វិញបាន។ ពេលដែលក្រុមការងាររបស់ខ្លួនជិះឡានត្រឡប់ទៅវិញ ស្រាប់តែមានប្រជាពលរដ្ឋមួយចំនួនជិះម៉ូតូដេញតាមឡានពីក្រោយ ហើយយកដុំថ្មគប់លើក្រុមការងាររបស់ខ្លួន ពេលនោះក្រុមការងារក៏ឈប់ឡានបំណងដើម្បីចាំគ្នាស្រាប់តែមានជនមិនស្គាល់ឈ្មោះ ដែលជិះម៉ូតូតាមពីក្រោយនោះបាននាំគ្នាមកវាយមកលើក្រុមការងាររបស់ខ្លួន ពេលដែលវាយនោះខ្លួន បានចូលទៅឃាត់ស្រាប់តែត្រូវគេវាយទាំងខ្លួនដែរ ដោយត្រូវចំមុខចំនួន០២ដៃផងដែរ។ រហូតដល់មានខាងអាជ្ញាធរមូលដ្ឋានចុះមកបំបែកទើបពួកប្រជាពលរដ្ឋទាំងនោះគេត្រឡប់ទៅវិញ។ ចំពោះអ្នកណាដែលស្រែកកំរាមសម្លាប់នោះក៏ខ្លួនមិនបានដឹងទេ ព្រោះខ្លួនទៅក្រោយគេ។ ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង និងសុំទាមទារសំណងចំនួន១០០លានរៀល ពីជនបង្កទាំងអស់នោះ។ នៅចំពោះមុខសវនាការបានឆ្លើយថា៖ ខ្លួនត្រូវគេវាយ ខ្លួនមិនស្គាល់អ្នកវាយនោះទេ ព្រោះពលរដ្ឋច្រើន ហើយគេវាយពីក្រោយ។ ខ្លួនមិនត្រូវរបួសធ្ងន់នោះទេ។ (មេធាវី [redacted] សួរ) ខ្លួនមិនបានអនុវត្តរុះរើសំណង់ទេ ព្រោះប្រជាពលរដ្ឋច្រើនពេកចូលរួម ហ៊ុំព័ទ្ធ ដើម្បីរារាំងមិនអោយអនុវត្ត។ (មេធាវី [redacted] សួរ)៖ ប្រជាពលរដ្ឋមកជុំគ្នាឈរជាធម្មតាទេ ជនជាប់ចោទទាំងពីរនេះ ខ្លួនមិនបានឃើញនោះទេ។ (មេធាវី [redacted] សួរ) ប្រជាពលរដ្ឋមាន ពូថៅ ដំបង ជប់ ផ្គាក់ ជាដើម ក្រុមការងារគិតថាបើយើងហ៊ានតែអនុវត្តនឹងមានហិង្សាពីពលរដ្ឋ។

(៥)- តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] យ៉េង បានឆ្លើយទៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ខ្លួន និងក្រុមការងារបានទៅចុះរុះរើសំណង់ខុសច្បាប់នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយអនុវត្តតាមបទបញ្ជារបស់ថ្នាក់លើ។ មុនពេលដែលខ្លួនចុះទៅអនុវត្ត គឺបានជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានដើម្បីចូលរួម ហើយពេលទៅដល់ទីកន្លែងកើតហេតុក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការនៃអាជ្ញាធរជាតិអប្សរា ដែលខ្លួននៅក្នុងនោះដែរ បានធ្វើការរុះរើរបង និងរោងរបស់ប្រជាពលរដ្ឋសាងសង់ខុសច្បាប់នៅលើដីទីនោះស្ថិតនៅក្នុងតំបន់២ នៃរមណីដ្ឋានអង្គរ ស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ នៅពេលដែលក្រុមការងារខ្លួនកំពុងធ្វើការរុះរើស្រាប់តែប្រជាជន

ដែលរស់នៅក្នុងភូមិអញ្ចាញទាំងអស់នាំគ្នាមករារាំងមិនឱ្យក្រុមការងារធ្វើការរុះរើ ដោយមានកាន់កាំបិត ពូថៅ ដំបង ខ្វែវ មកជាមួយធ្វើឱ្យក្រុមការងាររបស់ខ្លួនផ្អាកការអនុវត្តសិន។ ក្រោយមកខាងមូលដ្ឋានគាត់បានធ្វើការសម្របសម្រួលកុំឱ្យប្រជាពលរដ្ឋប្រើអំពើហិង្សាលើក្រុមការងារ ទើបក្រុមការងារខ្លួនអាចដកកម្លាំងត្រឡប់ទៅនាយកដ្ឋានសណ្តាប់ធ្នាប់វិញបាន។ ពេលដែលខ្លួន និងក្រុមការងារត្រឡប់ទៅវិញ នៅតាមផ្លូវស្រាប់តែមានប្រជាពលរដ្ឋមួយក្រុមជិះដេញតាមពីក្រោយដោយយកដុំថ្មគប់ត្រូវចំក្រុមការងារឈ្មោះ ជ័យ ស៊ីធុន និងស្រែកគំរាមកំហែងថា ចេញទៅបើចូលមកវិញយើងនឹងកាប់សម្លាប់។ ពេលនោះឈ្មោះ [redacted] វន បានប្រាប់តៃកុងឡានឈ្មោះ [redacted] ស្រស់ ថាមានគេគប់ត្រូវចំឈ្មោះ [redacted] ស៊ីធុល ហើយក៏នាំគ្នាឈប់ឡានដើម្បីមើលគ្នាថា គេគប់ត្រូវចំត្រង់ណា។ ពេលដែលក្រុមការងារឈប់ឡាននោះក៏មានប្រជាជនប្រហែល ២០ ម៉ូតូដែលជិះតាមដេញតាមពីក្រោយ ដោយស្រែកថាឈ្មោះ [redacted] ស្រស់ បើកឡានគៀពួកគេ ហើយពួកគេក៏ចាប់ក្របួចករអាវរបស់ឈ្មោះ [redacted] ស្រស់ វាយតែម្តង។ ពេលកើតហេតុនោះ ខ្លួននៅអង្គុយលើឡានខាងក្រោយស្រាប់តែមានជនមិនស្គាល់ឈ្មោះ ហក់មកវាយខ្លួនតែម្តងដោយវាយត្រូវចំមុខចំនួន០២ដៃ និងមួយដំបងឫស្សីទៀត ខ្លួនយកដៃរងធ្វើឱ្យបាក់ឫស្សីនោះត្រូវចំករបស់ខ្លួន។ ក្រោយមកមានអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចគាត់មកសម្របសម្រួល ប៉ុន្តែនៅមានបុរសម្នាក់មិនស្គាល់ឈ្មោះ តាមវាយក្រុមការងារខ្លួនទៀត តែវាយមិនត្រូវ ហើយឈ្មោះ [redacted] ស្រស់ គាត់បានបើកឡានគេចទៅមុខ ដោយមានទាំងជនសង្ស័យទៅជាមួយផងដែររហូតបើកឡានបានប្រហែល២គីឡូដី ក្រុមការងារខ្លួនឈប់ឡានឱ្យគាត់ចុះវិញរួចក៏នាំគ្នាត្រឡប់ទៅនាយកដ្ឋានវិញ។ ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង។

(៦)-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **ស៊ីធុន** បានឆ្លើយទៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ខ្លួន និងក្រុមការងារបានទៅចុះរុះរើសំណង់ខុសច្បាប់នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយអនុវត្តតាមបទបញ្ជារបស់ថ្នាក់លើ។ មុនពេលដែលខ្លួនចុះទៅអនុវត្ត គឺបានជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានដើម្បីចូលរួម ហើយពេលទៅដល់ទីកន្លែងកើតហេតុ ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការអាជ្ញាធរជាតិអប្សរា ដែលខ្លួននៅក្នុងនោះដែរបានធ្វើការរុះរើរបង និងរោងរបស់ប្រជាពលរដ្ឋសាងសង់ខុសច្បាប់នៅលើដីទំនេរស្ថិតនៅក្នុងតំបន់២នៃរមណីដ្ឋានអង្គរ ស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ នៅពេលដែលក្រុមការងារខ្លួនកំពុងធ្វើការរុះរើស្រាប់តែប្រជាជនដែលរស់នៅក្នុងភូមិអញ្ចាញទាំងអស់នាំគ្នាមករារាំងមិនឱ្យក្រុមការងាររុះរើ ដោយមានកាន់កាំបិត ពូថៅ ដំបង ខ្វែវ មកជាមួយ ធ្វើឱ្យក្រុមការងាររបស់ខ្លួនផ្អាកការអនុវត្តសិន។ ក្រោយមកខាងមូលដ្ឋានគាត់បានធ្វើការសម្របសម្រួលកុំឱ្យប្រជាពលរដ្ឋប្រើអំពើហិង្សាលើក្រុមការងារ ទើបក្រុមការងារខ្លួនក៏បានដកកម្លាំងត្រឡប់ទៅនាយកដ្ឋានសណ្តាប់ធ្នាប់វិញ។ ពេលដែលខ្លួន និងក្រុមការងារត្រឡប់ទៅវិញ នៅតាមផ្លូវស្រាប់តែមានប្រជាពលរដ្ឋមួយក្រុមជិះចេញតាមពីក្រោយដោយយកដុំថ្មគប់ត្រូវខ្លួន និងស្រែកគំរាមថា "ចេញទៅបើចូលមកវិញយើងនឹងកាប់សម្លាប់ចោលមិនថាជិះម៉ូតូ ឬជិះឡានក៏ដោយ"។ ពេលដែលគេគប់ដុំថ្មត្រូវគឺខ្លួនបានចុះពីលើឡានដើរទៅខាងមុខ ឡានស្រាប់តែឃើញប្រជាពលរដ្ឋម្នាក់ទៅវាយឈ្មោះ សំបុក វន ដោយវាយត្រូវពីចំក្រោយក្បាល។ ក្រោយមកមានអាជ្ញាធរមូលដ្ឋានទៅសម្រួលទើបពួកគេបំបែកគ្នាចេញ។ នៅចំពោះមុខសវនាការបានឆ្លើយថា ៖ មានពលរដ្ឋចំនួនពីរម៉ូតូ បានគប់លើក្រុមការងារ។ ជនល្មើសបានបុកឡើងលើឡាន ទើបខ្លួនចុះពីលើឡាន។ ចំពោះជនជាប់ចោទទាំងពីរនាក់នេះឈ្មោះ [redacted]

[redacted]ហ្សូរ ឈរថតវីដេអូរ តែពេលគប់ដុំថ្មមិនដឹងនរណាគប់ទេ។ (មេធាវី [redacted] សួរ) ខ្លួនឈរនៅមុខឡាន ឃើញឈ្មោះ [redacted]ហ្សូរ ឈរតែថតវីដេអូរទេ។ ចំពោះឈ្មោះ [redacted] ផល្លា ខ្លួនមិនបានឃើញទេ។ ទាំងព្រឹកទាំងរសៀល ខ្លួនមិនបានឃើញជនជាប់ចោទទាំងពីរនាក់នេះទេ។ ក្នុងរឿងនេះ ខ្លួនសុំឱ្យជួយរកយុត្តិធម៌ខ្លួនផង។

(៧)-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ឱន បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ និងក្រុមការងារបានទៅចុះរុះរើសំណង់ខុសច្បាប់នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយអនុវត្តតាមបទបញ្ជារបស់ថ្នាក់លើ។ មុនពេលដែលខ្លួនចុះទៅអនុវត្ត គឺបានជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានដើម្បីចូលរួម ហើយពេលទៅដល់ទីកន្លែងកើតហេតុ ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ នៃអាជ្ញាធរជាតិអប្សរា ដែលខ្លួននៅក្នុងនោះដែរ បម្រុងអនុវត្តវិធានការរដ្ឋបាលធ្វើការរុះរើរបងដែលសាងសង់ខុសច្បាប់នៅលើដីទីនោះស្ថិតនៅក្នុងតំបន់២ នៃរមណីដ្ឋានអង្គរ ស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ នៅពេលដែលក្រុមការងារខ្លួនបម្រុងអនុវត្តវិធានការរដ្ឋបាលធ្វើការរុះរើសំណង់ខុសច្បាប់ ស្រាប់តែប្រជាជនដែលរស់នៅក្នុងភូមិអញ្ចាញទាំងអស់នាំគ្នាមករារាំងមិនឱ្យក្រុមការងាររុះរើ ដោយមានកាន់កាំបិត ពូថៅ ដំបង ខ្វែង មកជាមួយធ្វើឱ្យក្រុមការងារផ្អាកការអនុវត្តសិន។ ក្រោយមកមានមូលដ្ឋានគាត់បានធ្វើការសម្រុះសម្រួលកុំឱ្យប្រជាពលរដ្ឋប្រើអំពើហិង្សាលើក្រុមការងារ ទើបក្រុមការងារខ្លួនអាចដកកម្លាំងត្រឡប់ទៅនាយកដ្ឋានសណ្តាប់ធ្នាប់វិញ។ ពេលដែលក្រុមការងាររបស់ខ្លួនជិះឡានត្រឡប់ទៅវិញ ស្រាប់តែប្រជាពលរដ្ឋមួយចំនួនជិះម៉ូតូដេញតាមឡានពីក្រោយ ហើយយកដុំថ្មគប់លើក្រុមការងាររបស់ខ្លួន និងកាត់ឡានក្រុមការងារឱ្យឈប់ឡាន ពេលនោះក្រុមការងារខ្លួនបានឈប់ឡានស្រាប់តែមានជនមិនស្គាល់ឈ្មោះ ដែលជិះម៉ូតូតាមពីក្រោយនោះបាននាំគ្នាចាប់តែកុងឡានឱ្យចេញពីឡាន ហើយឡើងលើឡានរបស់ពួកខ្លួនក្នុងបំណងវាយពួកខ្លួន ពេលនោះខ្លួនក៏ចុះពីលើឡានស្រាប់តែត្រូវពួកគេវាយលើខ្លួនត្រូវចំក្បាលចំនួន០៣ដែបណ្តាលឱ្យខ្លួនរងរបួស។ រហូតដល់មានខាងអាជ្ញាធរមូលដ្ឋានចុះមកធ្វើការសម្របសម្រួលទើបពួកប្រជាពលរដ្ឋទាំងនោះក៏ត្រឡប់ទៅវិញ។ ក្រោយពីពួកគេវាយមកលើក្រុមការងារខ្លួនរួចពួកគេថែមទាំងគំរាមថា "បើថ្ងៃក្រោយចុះមកភូមិអញ្ចាញទៀត ពួកគេនឹងកាប់សម្លាប់ និងដុតបំផ្លាញរថយន្តរបស់ក្រុមការងារខ្លួនចោល។ នៅចំពោះមុខសវនាការបានឆ្លើយថា ៖ ពេលព្រឹកខ្លួនចុះទៅរើ ក្រុមការងារមិនអាចអនុវត្តបានព្រោះប្រជាពលរដ្ឋមានកាន់កាំបិត ខ្វារ ជាដើម ពេលរសៀលក៏ចុះទៅម្តងទៀត តែក្រុមការងារឃើញមានប្រជាពលរដ្ឋជាច្រើនជិះម៉ូតូជាច្រើននាក់តាមក្រុមការងារ រហូតមានការចុះស្កាត់មុខឡាន។ មានបុគ្គលបួននាក់ជិះម៉ូតូពីរគ្រឿងបានជិះម៉ូតូវ៉ាឡាន ស្កាត់ឡាន និងគប់ដុំថ្មលើក្រុមការងារទៀត។ ពេលចេញពីកន្លែងត្រូវរុះរើ ជិះចេញមកតាមផ្លូវទើបមានការប្រើប្រាស់ហិង្សាលើក្រុមការងារ។ (មេធាវី [redacted] សួរ) ៖ ថ្ងៃនោះមិនបានរុះរើសំណង់នោះទេ ដោយសារពលរដ្ឋឈររារាំងការពារមិនអោយរុះរើ។ (មេធាវី [redacted] សួរ) រារាំងដោយពលរដ្ឋជាច្រើននាក់ ខ្លួនមិនចាំបុគ្គលទេ។ ពេលជិះចេញពលរដ្ឋឈរពាំងមុខឡាន។ អំពើហិង្សាកើតឡើងពេលរសៀលពេលក្រុមការងារជិះចេញពីកន្លែងរុះរើសំណង់។ ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង និងសុំទាមទារសំណងចំនួន១០០ លានរៀល ពីជនបង្កទាំងអស់នោះ។

(៨)-តាមការចម្លើយរបស់សាក្សីឈ្មោះ [redacted] សារ៉ាត់ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២២ ខែ មិថុនា ឆ្នាំ២០២២ មានពេលនោះខ្លួនកំពុងជាប់រវល់ប្រជុំនៅស្នាក់ការភូមិ ប្រហែលម៉ោង ០៣



Scanned with CamScanner

និងសាមសិបនាទីរសៀល ស្រាប់តែមានប្រជាការពារភូមិបានខលទូរស័ព្ទមកប្រាប់ខ្លួនថា ប្រជាជនប្រហែល ៣០០ នាក់បានហ៊ុំឃាត់ឡានក្រុមការងារអាជ្ញាធរអប្សរាមិនអោយចាកចេញពីភូមិអញ្ចាញ ហើយសុំឱ្យខ្លួនមកជួយសម្របសម្រួលឱ្យក្រុមការងារអាជ្ញាធរអប្សរាបានចេញពីទីតាំងកើតហេតុផង។ ក្រោយពេលដែលខ្លួនទៅដល់កន្លែងកើតហេតុ ខ្លួនបានសម្របសម្រួលប្រជាពលរដ្ឋដើម្បីឱ្យក្រុមការងារអាជ្ញាធរអប្សរាចេញពីកន្លែងកើតហេតុ ប៉ុន្តែពេលដែលខ្លួនទៅដល់នោះខ្លួនមិនបានឃើញអ្នកណាវាយអ្នកណា និងគំរាមគំហែងលើខាងមន្ត្រីអាជ្ញាធរអប្សរាអ្វីឡើយ ព្រោះខ្លួនទៅដល់ក្រោយពេលកើតហេតុ។

(៩)-តាមការចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ឝា បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ខ្លួន និងក្រុមការងារបានទៅចុះរុះរើសំណង់ខុសច្បាប់នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយអនុវត្តតាមបទបញ្ជារបស់ថ្នាក់លើ។ មុនពេលដែលខ្លួនចុះទៅអនុវត្ត គឺបានជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានដើម្បីចូលរួម ហើយពេលទៅដល់ទីកន្លែងកើតហេតុ ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ នៃអាជ្ញាធរជាតិអប្សរា ដែលខ្លួននៅក្នុងនោះដែរ បម្រុងអនុវត្តវិធានការរដ្ឋបាលធ្វើការរុះរើរបងដែលសាងសង់ខុសច្បាប់នៅលើដីទីនេះ ស្ថិតនៅក្នុងតំបន់២ នៃរមណីដ្ឋានអង្គរ ស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ នៅពេលដែលក្រុមការងារខ្ញុំបម្រុងអនុវត្តវិធានការរដ្ឋបាលធ្វើការរុះរើសំណង់ខុសច្បាប់ សម្រាប់តែប្រជាជនដែលរស់នៅក្នុងភូមិអញ្ចាញទាំងអស់នាំគ្នាមករារាំងមិនឱ្យក្រុមការងាររុះរើ ដោយមានកាន់កាបិត ពូថៅ ដំបង ខ្សែវ មកជាមួយធ្វើឱ្យក្រុមការងាររបស់ខ្លួនផ្អាកការអនុវត្តសិន។ ក្រោយមកខាងមូលដ្ឋានគាត់បានធ្វើការសម្របសម្រួលកុំឱ្យប្រជាពលរដ្ឋប្រើអំពើហិង្សាលើក្រុមការងារ ទើបក្រុមការងារខ្លួនអាចដកកម្លាំងត្រឡប់ទៅនាយកដ្ឋានសណ្តាប់ធ្នាប់វិញ។ ពេលដែលខ្លួន និងក្រុមការងារត្រឡប់ទៅវិញនៅតាមផ្លូវ ស្រាប់តែមានប្រជាពលរដ្ឋមួយក្រុមជិះដេញតាមពីក្រោយប្រហែល ២០០ម៉ែត្រ ដោយខ្លួនក៏ស្ថិតនៅក្នុងឡានរបស់ក្រុមការងារផងដែរ។ ពេលនោះមានប្រជាពលរដ្ឋចំនួន ០២នាក់ ជិះម៉ូតូ មកជិតរថយន្តរបស់ក្រុមការរបស់ខ្លួន ហើយបានផាក់ទ្វាឡានរួចស្រែកថា ពួកខ្លួនជិះឡានគៀរពួកគេ ដើម្បីឱ្យគ្នាគាត់ដទៃទៀតមានកំហឹងមកលើពួកក្រុមការងារខ្លួន បន្ទាប់មកមានគ្នាគាត់ផ្សេងទៀតយកដុំថ្មគប់ត្រូវឈ្មោះ [redacted]ស៊ីធុន និងមានគប់ស្បែកជើងត្រូវចំឈ្មោះ [redacted] យ៉េង រួចបានបើកម៉ូតូ ទៅឃាត់ឡានឱ្យឈប់ ថែមទាំងចាប់ទាញតៃកុងឡានដែលមានឈ្មោះ [redacted] ស្រស់ ចេញពីឡាននឹងវាយលើគាត់ ព្រមទាំងឡើងមកវាយក្រុមការងារខ្លួន ដែលនៅលើឡានដែលត្រូវចំឈ្មោះ [redacted] ស៊ីធុន ឈ្មោះ [redacted] យ៉េង ឈ្មោះ [redacted] វន និងឈ្មោះ [redacted] សុខ ថែមទៀត។ ហើយឈ្មោះ [redacted] គីមហួរ បានស្រែកគំរាមថា ឱ្យប្រជាពលរដ្ឋចាប់ពួកខ្លួនចងទុកដើម្បីឱ្យមេវាមកដោះស្រាយ។ ក្រោយអាជ្ញាធរមូលដ្ឋានមកហាមឃាត់ទើបពួកគេព្រមឱ្យពួកខ្លួនចេញ តែមានឈ្មោះ [redacted]ផល្លា បានស្រែកគំរាមថា ដោះលែងពួកវាហើយកុំឱ្យពួកវាមកជាន់ទឹកដីភូមិអញ្ចាញទៀតបើមិនដូច្នេះទេ ទោះបីជិះកង់ ម៉ូតូ ឬ ឡានចូលក្នុងភូមិអញ្ចាញម្តងទៀត និងកាប់សម្លាប់ចោល និងឱ្យប្រជាពលរដ្ឋចាំមុខពួកខ្លួនទុក។ នៅមុខសវនាការបានឆ្លើយថា ៖ ក្រុមការងារចុះទៅរើរបង់ មិនបានរើ ដោយសារមានប្រជាពលរដ្ឋជិតបួនរយនាក់ចុះមករារាំង និងនិយាយថាបើហ៊ានតែរើនឹងកាប់សម្លាប់តែម្តង។ ក្រុមការងារក៏ចាកចេញពីកន្លែង ពលរដ្ឋបានជិះដេញតាមឡាន កាក់មុខឡាន ទាញតៃកុងឡានវាយតែម្តង ក្រុមការងារជិះក្រោយឡានក៏ត្រូវពលរដ្ឋវាយផងដែរ។ ប្រជាពលរដ្ឋម្នាក់បានជិះឡានជាមួយក្រុមការងារនៅឡានដំបូង ប្រជាពលរដ្ឋថាបើមិនអោយពលរដ្ឋ



Scanned with CamScanner

ម្នាក់នេះមកវិញទេ កុំសង្ឃឹមថាឡានមួយទៀតអាចចេញបាន។ ខ្លួនចំណាំឈ្មោះ [redacted]ហួរ ដែលឈរថតវីដេអូរ។ ឈ្មោះ [redacted]ហួរ ឈរតែថតវីដេអូរទេ។ ឈ្មោះ ហួរ មិនបានធ្វើសកម្មភាពរាំងស្រែកអ្វីទេ។

(១០)-តាមចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ទី បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០១ និង៣០នាទីរសៀល ប្រជាការពារភូមិបានទាក់ទងហៅខ្លួនឱ្យទៅជួយមើលរឿងប្រជាពលរដ្ឋហ៊ុំព័ទ្ធឡានរបស់អាជ្ញាធរអប្សរា។ ពេលដែលខ្លួនទៅដល់កន្លែងកើតហេតុ ខ្លួនមិនបានឃើញនរណាវាយទៅលើមន្ត្រីអាជ្ញាធរអប្សរានោះទេ ព្រោះខ្លួនទៅដល់កន្លែងកើតហេតុឃើញត្រឹមតែប្រជាពលរដ្ឋហ៊ុំព័ទ្ធឡានតែប៉ុណ្ណឹង និងខ្លួនបានឃើញឈ្មោះ [redacted] គីមហួរ កាន់ទូរស័ព្ទដៃឈរថតនៅក្បែរដើមឈើកន្លែងកើតហេតុ។ មូលហេតុដែលប្រជាពលរដ្ឋប្រហែល ៣០០ ទៅ ៤០០នាក់ ទៅហ៊ុំព័ទ្ធឡានរបស់មន្ត្រីអាជ្ញាធរជាតិអប្សរា ព្រោះអាជ្ញាធរអប្សរាចុះទៅរុះរើសំណង់ ដែលសាងសង់នៅលើដីដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា ហើយមុនពេលដែលអាជ្ញាធរជាពិអប្សរាចុះទៅដើម្បីរុះរើនោះ គឺបានជូនដំណឹងមកខាងភូមិឃុំឱ្យចូលរួចជាមួយអាជ្ញាធរជាតិអប្សរាដែល។ ក្រោយពេលដែលខ្លួនទៅដល់កន្លែងកើតហេតុ ខ្លួនបានសម្របសម្រួលប្រជាពលរដ្ឋឱ្យបំបែកគ្នា និងបើកផ្លូវឱ្យអាជ្ញាធរអប្សរាចេញ ទើបប្រជាពលរដ្ឋព្រមបើកផ្លូវឱ្យអាជ្ញាធរជាតិអប្សរាចេញត្រឡប់ទៅវិញ។ ចំពោះអ្នកណាស្រែកគំរាមទៅកាន់មន្ត្រីអាជ្ញាធរជាតិអប្សរាខ្លួនអត់ដឹងទេ ព្រោះប្រជាជនមានគ្នាច្រើនមកពីភូមិផ្សេងទៀត ដូចនេះខ្លួនមិនដឹងថាមានអ្នកស្រែកគំរាម ឬ អត់ទេព្រោះខ្លួនរវល់តែសម្របសម្រួលនៅខាងជើងទំនប់អញ្ចាញមួយកន្លែង និងនៅខាងត្បូងសាលាឆទានមួយកន្លែងទៀត។ នៅចំពោះមុខសវនាការបានឆ្លើយថា៖ ខ្លួនទៅឃើញប្រជាពលរដ្ឋកំពុងកាក់ឡានអប្សរាមួយ។ ខ្លួនឃើញឈ្មោះ[redacted] ជរ ឃើញអាជ្ញាធរអប្សរា ខ្លួនមិនបានឃើញឈ្មោះ [redacted] ផល្លា ទេព្រោះមនុស្សមានច្រើន។ (មេធាវី [redacted]សួរ) ពេលព្រឹកខ្លួនចូលរួមម្តង ពេលរសៀលខ្លួនបានចូលរួមម្តងទៀត។ ឡានអាជ្ញាធរបើកចេញប្រជាពលរដ្ឋបានហ៊ុំព័ទ្ធម្តងទៀតនៅជាប់ឡានមួយគ្រឿង។ ឈ្មោះ ហួរ នៅឈរជិតប្រហែលដប់ម៉ែត្រ។

(១១)-តាមចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សឿន បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ មានប្រជាពលរដ្ឋនៅភូមិអញ្ចាញបានមកហៅខ្លួនឱ្យទៅជួយសម្របសម្រួលរឿងប្រជាពលរដ្ឋទៅឃាត់ឡានរបស់អាជ្ញាធរជាតិអប្សរា ពេលដែលខ្លួនទៅដល់កន្លែងកើតហេតុ ខ្លួនបានឃើញប្រជាពលរដ្ឋប្រហែល ៣០០ ទៅ ៤០០ នាក់ ធ្វើការឃាត់ឡានរបស់អាជ្ញាធរអប្សរា ព្រោះមន្ត្រីអាជ្ញាធរជាតិអប្សរាទៅធ្វើការរុះរើផ្ទះរបស់ពួកគេ ប៉ុន្តែនៅថ្ងៃកើតហេតុនោះមិនទាន់មានការរុះរើអ្វីនោះទេ។ ពេលដែលខ្លួនទៅដល់នោះ គឺខ្ញុំសម្រួលប្រជាពលរដ្ឋឱ្យបើកផ្លូវឱ្យអាជ្ញាធរអប្សរាចេញត្រឡប់ទៅវិញ។ ខ្លួនមិនដឹងថាមានអ្នកណាស្រែកគំរាមទៅមន្ត្រីអាជ្ញាជាតិអប្សរានោះទេ ព្រោះពេលដែលខ្លួនសម្រួលចប់ ខ្លួនក៏ត្រឡប់ទៅស្នាក់ការភូមិវិញ។ នៅកន្លែងកើតហេតុនោះខ្លួនបានឃើញឈ្មោះ [redacted] គីមហួរ ដែរ ដោយគេបានកាន់ទូរស័ព្ទឈរថតនៅក្បែរដើមឈើ។ បានជាខ្លួនបានស្គាល់ឈ្មោះ មឿង គីមហួរ ព្រោះគេជាអ្នកជិតខាងរបស់ខ្លួន ចំណែកអ្នកផ្សេងទៀតដែលនៅទីនោះដែរ ខ្លួនមិនស្គាល់ពួកគេទេ។

(១២)-តាមចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ៩រ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ខ្លួន និងក្រុមការងារបានទៅចុះរុះរើសំណង់ខុសច្បាប់នៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុង



Scanned with CamScanner

សៀមរាប ខេត្តសៀមរាប ដោយអនុវត្តតាមបទបញ្ជារបស់ថ្នាក់លើ។ មុនពេលដែលខ្លួនចុះទៅអនុវត្តក៏បានជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានដើម្បីចូលរួម ហើយពេលទៅដល់ទីកន្លែងកើតហេតុ ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការនៃអាជ្ញាធរជាតិអប្សរាដែលខ្លួននៅក្នុងនោះដែរ បម្រុងអនុវត្តវិធានការរដ្ឋបាលធ្វើការរុះរើរបងដែលសាងសង់ខុសច្បាប់នៅលើដីទំនេរ ស្ថិតនៅក្នុងតំបន់២ នៃរមណីដ្ឋានអង្គរស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ នៅពេលដែលក្រុមការងារខ្លួនបម្រុងអនុវត្តវិធានការរដ្ឋបាលធ្វើការរុះរើសំណង់ខុសច្បាប់សម្រាប់តែប្រជាជនដែលរស់នៅក្នុងភូមិអញ្ចាញទាំងអស់ នាំគ្នាមករារាំងមិនឱ្យក្រុមការងាររុះរើដោយមានកាន់កាបិត ពូថៅ ដំបង ខ្វែវ មកជាមួយ ធ្វើឱ្យក្រុមការងាររបស់ខ្លួនផ្អាកការអនុវត្តសិន។ ក្រោយមកខាងមូលដ្ឋានគាត់បានធ្វើការសម្របសម្រួល កុំឱ្យប្រជាពលរដ្ឋអំពីហិង្សាលើក្រុមការងារ ទើបក្រុមការងារខ្លួនអាចដកកម្លាំងត្រឡប់ទៅយកដ្ឋានសណ្តាប់ធ្នាប់វិញ។ ពេលដែលខ្លួន និងក្រុមការងារត្រឡប់ទៅវិញនៅតាមផ្លូវស្រាប់តែមានប្រជាពលរដ្ឋមួយក្រុមជិះដេញតាមពីក្រោយប្រហែល ២០០ម៉ែត្រ ដោយខ្លួនក៏ស្ថិតនៅក្នុងឡានរបស់ក្រុមការងារផងដែរ។ ពេលនោះមានប្រជាពលរដ្ឋចំនួន០២នាក់ ជិះម៉ូតូមកជិតរថយន្តរបស់ពួកខ្លួនហើយបានធាក់ទ្វាឡានរួចស្រែកថាពួកខ្លួនជិះឡានគៀរពួកគេ ដើម្បីឱ្យគ្នាគាត់ដទៃទៀតមានកំហឹងមកលើពួកក្រុមការងារខ្លួន បន្ទាប់មកមានគ្នាគាត់ផ្សេងទៀតយកដុំថ្មគប់ត្រូវឈ្មោះ [redacted] ស៊ីធុន និងមានគប់ស្បែកជើងត្រូវចំឈ្មោះ [redacted] យ៉ង់ រួចបានបើកម៉ូតូទៅឃាត់ឡានឱ្យឈប់ថែមទាំងចាប់ទាញតៃកុងឡានដែលមានឈ្មោះ [redacted] ស្រស់ ចេញពីឡាននឹងវាយលើគាត់ព្រមទាំងឡើងមកវាយក្រុមការងារខ្លួនដែលនៅលើឡាន ដែលត្រូវចំឈ្មោះ [redacted] ស៊ីធុន ឈ្មោះ [redacted] យ៉ង ឈ្មោះ [redacted] វន និងឈ្មោះ [redacted] សុខ ថែមទៀត។ ហើយឈ្មោះ [redacted] គឹមហ្សួរ បានស្រែកគំរាមថា ឱ្យប្រជាពលរដ្ឋចាប់ពួកខ្លួនចងទុកដើម្បីឱ្យមេវាមកដោះស្រាយ ក្រោយអាជ្ញាធរមូលដ្ឋានមកហាមឃាត់ ទើបពួកគេព្រមឱ្យពួកខ្លួនចេញតែមានឈ្មោះ [redacted] ផល្លា បានស្រែកគំរាមថា ដោះលែងពួកវាហើយកុំឱ្យពួកវាមកជាន់ទឹកដីភូមិអញ្ចាញទៀត បើមិនដូច្នេះទេទោះបីជិះកង់ ម៉ូតូ ឬ ឡាន ចូលក្នុងភូមិអញ្ចាញម្តងទៀត និងកាប់សម្លាប់ចោល និងឱ្យប្រជាពលរដ្ឋចាំមុខពួកខ្លួនទុក។ នៅចំពោះមុខសសវនាការបានឆ្លើយថា៖ ខ្លួនជានគរបាលបេតិកភណ្ឌ នៅថ្ងៃកើតហេតុឃើញមានជនជាប់ចោទទាំងពីរនាក់នេះ ពេលព្រឹកឃើញឈ្មោះ [redacted] ហ្សួរ ច្បាស់ជិះម៉ូតូឆ្នែល ចំណែកពេលព្រឹកមិនឃើញឈ្មោះ ផល្លា នោះទេ។ ពេលរសៀលក៏ឃើញដែរឃើញឈ្មោះ គឹមហ្សួរ ជិះជាមួយប្រជាពលរដ្ឋដែរ ឈ្មោះ [redacted] ផល្លា នៅជួឈ្មោះ សុទ្ធ សេរ តែមានគ្នាគាត់បួនប្រាំនាក់ផងដែរ។ ពេលមានហិង្សាអ្នកទាំងពីរនាក់នេះ បានចូលទៅក្នុងហេតុការនឹងបានស្រែកថាអោយកាក់ក្រុមអប្សរាមិនអោយចេញជាសម្តីរបស់ឈ្មោះ ហ្សួរ ចំណែកឈ្មោះ ផល្លា បានចង្អុលខ្លួនថាខ្លួនជាមេក្លោងនាំអប្សរអោយចូលមករើសំណង់ និងបានអោយពលរដ្ឋចាំមុខខ្លួនថានឹងសម្លាប់ខ្លួន។ ឈ្មោះ ហ្សួរ និយាយហើយចង្អុលទៅលើក្រុមការងារ។ មានតែខ្លួនទេដែរស្គាល់មុខ ចំពោះក្រុមការងារមិនស្គាល់មុខសញ្ញានោះទេ។ និយាយថាកាក់ក្រុមការងារទុកសិនចាំអោយមេវាមកដោះស្រាយសិន។ ឈ្មោះ [redacted] ផល្លា ពេលមេភូមិជួយដោះបានចង្អុលមុខខ្លួនថា ខ្លួនជាមេក្រុមហៅអប្សរមករើ បើមានការចូលភូមិអោយសម្លាប់ចោល ក្រុមការងារក៏បានលឺដែរ គ្រាន់តែក្រុមការងារមិនស្គាល់ឈ្មោះ មានតែខ្លួនបានស្គាល់មុខសញ្ញាច្បាស់។ (មេធាវី [redacted] ស្ទួរ) ខ្លួនចង់ចាំជនល្មើសទាំងពីរនាក់នេះ ដោយសារជនល្មើសពីរនាក់នេះនៅជិតខ្លួន ហើយពីរនាក់នេះបានចង្អុលមុខខ្លួន និងបានស្រែកមកលើរូបខ្លួន។

(១៣)-តាមការចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សេរ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជម្រះក្តីស្រដៀងគ្នាថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ១ ប្រហែល៤០នាទីរសៀល លោកមេប៉ុស្តិ៍នគរបាលសង្កាត់នគរធំ បានទាក់ទងមកខ្លួនតាមរយៈអាយគូម ដោយបានប្រាប់ថា មានប្រជាពលរដ្ឋកំពុងមានទំនាស់ជាមួយអាជ្ញាធរអប្សរា ឱ្យខ្លួនទៅមើលដោយពេលនោះខ្លួនកំពុងអង្គុយនៅផ្ទះរបស់ខ្លួនអង្គុយជជែកគ្នាលេងជាមួយឈ្មោះ [redacted] ផល្លា ដោយសារតែឈ្មោះ [redacted] ផល្លា គាត់មកផ្ទះខ្លួនតាំងពីម៉ោង ១១ កន្លះ ហើយខ្លួនក៏បបួលឈ្មោះ [redacted] ផល្លា ទៅមើលគេឈ្លោះគ្នារវាងប្រជាជន និងអាជ្ញាធរអប្សរា រួចខ្លួនក៏បើកម៉ូតូឌុបឈ្មោះ [redacted] ផល្លា ដើម្បីទៅមើលទាំងអស់គ្នាតាមបទបញ្ជារបស់មេប៉ុស្តិ៍ផង។ ក្រោយពេលដែលខ្លួន និងឈ្មោះ [redacted] ផល្លា ទៅដល់កន្លែងកើតហេតុគឺខាងមន្ត្រីអាជ្ញាធរជាតិអប្សរា គាត់បានចាកចេញទៅបាត់អស់ហើយនៅសល់តែប្រជាជនប្រហែល ៣០០នាក់ ដែលមិនទាន់បំបែកគ្នា ហើយខ្លួនក៏បានប្រាប់ប្រជាជនឱ្យឆាប់បំបែកគ្នាទៅផ្ទះទៅ កុំឱ្យនៅផ្តុំគ្នាទៀត ប្រយ័ត្នប៉ូលីសប៉េអឹមមកចាប់។ បន្ទាប់ មកខ្លួនក៏ឌុបឈ្មោះ [redacted] ផល្លា ទៅផឹកកាហ្វេនៅផ្លូវ៦០ ម៉ែត្រ ប្រហែលកន្លះម៉ោងក្រោយមកមានគេប្រាប់ថាប្រជាជនបានបំបែកគ្នាអស់ហើយ ហើយខ្លួនក៏រាយការណ៍ទៅលោកមេប៉ុស្តិ៍បន្ត។ ចំពោះឈ្មោះ យី ផល្លា គឺគាត់មិនបាននិយាយអ្វីទាំងអស់ ពេលដែលខ្លួនឌុបគាត់ទៅដល់កន្លែងកើតហេតុ ហើយគាត់ក៏មិនបានស្រែកគំរាមអ្នកណាឡើយ ដោយគាត់អង្គុយនៅលើម៉ូតូនៅក្រោយខ្នងខ្លួន រហូតមិនបានចុះទៅណាទេ។ ចំពោះរូបថតរបស់ឈ្មោះ [redacted] ផល្លា ដែលអង្គុយលើតុនោះគឺជារូបដែលគាត់អង្គុយនៅផ្ទះរបស់ខ្លួន។ នៅចំពោះមុខសវនាការបានឆ្លើយបន្ថែមថាឈ្មោះ [redacted] ផល្លា គាត់ទៅអង្គុយផ្ទះខ្លួន ពេលមានរឿងខ្លួនក៏ឌុបគាត់ទៅមើលកន្លែងដែលពលរដ្ឋកាក់អប្សរា។ ខ្លួនដឹកគាត់ទៅដើម្បីទៅអង្គុយមើលអប្សរាដែលត្រូវពលរដ្ឋកាក់ ខ្លួនជិះទៅជាមួយឈ្មោះ [redacted] ផល្លា តែពីរនាក់ទេ។ (មេធាវី [redacted] សួរ) ឈ្មោះ [redacted] ផល្លា ត្រូវជាបងធម៌រាប់អានគ្នាខ្លួនជាប៉ូលីសប៉ុស្តិ៍។ ទៅមើលកន្លែងប្រជាពលរដ្ឋកាក់អប្សរានៅសាលារៀនមេថាបើមានបញ្ហាអោយខ្លួនជួយសម្របសម្រួល។ ពេលព្រឹកខ្លួនមិនដឹងថាឈ្មោះ [redacted] ផល្លា បានធ្វើសកម្មភាពអ្វីខ្លះនោះទេ។ (មេធាវី [redacted] សួរ) ខ្លួនជានគរបាលប៉ុស្តិ៍សង្កាត់នគរធំ ឈ្មោះ [redacted] ផល្លា អោយតែមកពីបាត់ដំបងតែមកអង្គុយលេងផ្ទះខ្លួនដូចជាទម្លាប់។ ខ្លួនទទួលព័ត៌មានពីមេប៉ុស្តិ៍ថាអោយទៅមើលពលរដ្ឋកាក់ឡានអប្សរា ហើយមេប៉ុស្តិ៍អោយខ្ញុំទៅមើលដើម្បីសម្របសម្រួល ហើយខ្លួនក៏នាំឈ្មោះ [redacted] ផល្លា ទៅដែរអោយបានគ្នា។ ពេលដល់កន្លែងកើតហើយ ឃើញអប្សរាដកឡានចេញ ទៅបាត់ហើយ ឈ្មោះ យី ផល្លា នៅឈរជាជិតខ្លួន។ ចំណែកឈ្មោះ [redacted] ជរ ខ្លួនស្គាល់ច្បាស់ដោយសារជាក្រុមការងារចុះរុះរើ តែខ្លួនមិនបានឃើញឈ្មោះ [redacted] ជរ នៅកន្លែងកើតហេតុនោះទេ។ (មេធាវី [redacted] សុំសួរតទល់រវាងសាក្សីឈ្មោះ [redacted] ជរ និងឈ្មោះ [redacted] សេរ) [redacted] ជរ ថាឃើញឈ្មោះ [redacted] សេរ ទៅជួយសម្រួលការងារ ពេលឈ្មោះ [redacted] ផល្លា ចង្អុលមុខខ្លួន ខ្លួនឃើញឈ្មោះ [redacted] សេរ ជួយសម្របសម្រួល។ ខ្លួនដឹងឈ្មោះ [redacted] ផល្លា ទៅម៉ោងមួយជាង។

(១៤)-តាមចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ឡៀង បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ មន្ត្រីអាជ្ញាធរជាតិអប្សរាចុះមករុះរើសំណង់នៅក្នុងភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយពេលនោះខ្លួនក៏បានចូលរួមទៅជាមួយផងដែរ។ ពេលទៅដល់ទីតាំងដែលត្រូវរុះរើនោះស្រាប់តែមានប្រជាពលរដ្ឋប្រហែល ៣០០ ទៅ ៤០០ នាក់ មកធ្វើការហាមឃាត់មិនឱ្យរុះរើសំណង់ ដោយខ្លួនមិនបានឃើញប្រជាពលរដ្ឋមានកាន់អាវុធមកជាមួយនោះទេ ប៉ុន្តែពេលនោះខ្លួនបានឃើញឈ្មោះ មឿង គឹមហួរ នៅ



Scanned with CamScanner

ទីនោះដែល ដោយគាត់បានដកទូរស័ព្ទយកមកថតតែពុំមានធ្វើសកម្មភាពផ្សេងទេ។ ក្រោយពីឃើញប្រជាពលរដ្ឋច្រើនបែបនេះ ខ្លួននឹងមន្ត្រីអាជ្ញាធរជាតិអប្សរាក៏បំបែកគ្នាត្រឡប់ទៅវិញ ដោយខ្លួនត្រឡប់ទៅផ្ទះរបស់ខ្លួន ហើយខាងមន្ត្រីគេត្រឡប់ទៅកន្លែងគេវិញ តែខ្លួនមិនបានឃើញប្រជាពលរដ្ឋដេញតាមពេលខ្លួនត្រឡប់ទៅផ្ទះវិញនោះទេ។ ក្រោយមកស្រាប់តែមានខាងសាលាសង្កាត់បានទាក់ទងមកខ្លួនម្តងទៀតដោយប្រាប់ថា មានបញ្ហាប្រជាពលរដ្ឋជាច្រើននាក់ទៅឃាត់ឡានរបស់អាជ្ញាធរជាតិអប្សរា ហើយឱ្យខ្លួនទៅជួយសម្របសម្រួល។ ក្រោយពេលដែលខ្លួនទៅដល់កន្លែងកើតហេតុ គឺខ្លួនមិនបានឃើញអ្នកណាវាយអ្នកណានោះទេ ហើយក៏មិនបានឃើញឈ្មោះ [redacted] គីមហ្សូរ នៅទីនោះដែរ ព្រោះពេលដែលខ្លួនទៅដល់គឺខ្លួនគ្រាន់តែសម្របសម្រួលឱ្យប្រជាពលរដ្ឋបើកផ្លូវឱ្យអាជ្ញាធរជាតិអប្សរាចាកចេញពីកន្លែងកើតហេតុតែប៉ុណ្ណោះ រឿងអ្វីផ្សេងខ្លួនមិនបានដឹងលឺនោះទេ។

**(១៥)- សេចក្តីសន្និដ្ឋានការពាររបស់សហមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី លោក [redacted] សុខុនា និងលោកស្រី [redacted] សុខុនទូន** ថា ៖ ពិតជាមានអង្គហេតុនៃការរារាំងការអនុវត្តរបស់ក្រុមការងាររបស់អាជ្ញាធរ អប្សរាពិតមែនដូចមានក្នុងដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។ សាក្សីឈ្មោះ [redacted] ជរ បានចាំបាននូវបុគ្គលដែលបានធ្វើសកម្មភាពចង្អុលមុខមកលើរូបគាត់។ ឈ្មោះ [redacted]ហ្សូរ ជាអ្នកជិះម៉ូតូដើរប្រមូលអ្នកភូមិមកប្រចាំតវ៉ាជាមួយអាជ្ញាធរ។ ឈ្មោះ [redacted] ផល្លា ជាអ្នកចង្អុលមុខសាក្សីឈ្មោះ [redacted] ជរ អោយជិះចេញទៅកុំអោយចូលទៅភូមិអញ្ចាញកុំអោយចូលភូមិអញ្ចាញទៀតបើចូលមកឃើញនឹងសម្លាប់។ ពលរដ្ឋជាច្រើន តែហេតុអ្វីបានអប្សរាមិនប្តឹងបែរជាមកប្តឹងជនល្មើសតែពីរនាក់នេះព្រោះសាក្សីឈ្មោះ [redacted] ជរ ចាំតែជនជាប់ចោទតែពីរនាក់នេះ។ ខ្លួនសន្និដ្ឋានថាជនជាប់ចោទទាំងពីរនាក់នេះពិតជាបានប្រព្រឹត្តអំពើដូចបទចោទប្រកាន់របស់តំណាងអយ្យការ និងចៅក្រមស៊ើបសួរមែន។ ចំពោះការចោទប្រកាន់ពីបទហិង្សាមិនគ្រប់គ្រាន់ទេ ព្រោះមានដុំថ្ម និងមនុស្សច្រើន សុំប្តូរបទចោទជាបទហិង្សាមានស្ថានទម្ងន់តាមមាត្រា២១៨វិញ សុំផ្តន្ទាទោសតាមច្បាប់ និងសំណងជម្ងឺចិត្ត១០០លានរៀល។

**(១៦)- សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ** សុំតម្កល់បទចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៣៤២ អយក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ពោល គឺតម្កល់បទចោទប្រកាន់លើជនជាប់ចោទទាំង០២នាក់ ខាងលើដែលមានឈ្មោះ [redacted] ផល្លា និងឈ្មោះ [redacted] គីមហ្សូរ ពីបទ "ប្រឆាំងនឹងការអនុវត្តការងារសាធារណៈហិង្សាដោយចេតនា និងគំរាមគំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ" ប្រព្រឹត្តនៅចំណុចភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥០៦ មាត្រា២១៧ និងមាត្រា២៣៤ នៃក្រមព្រហ្មទណ្ឌ។ តុលាការយល់ឃើញថា សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការនេះមានលក្ខណៈត្រឹមត្រូវ។

**(១៧)- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ លោក [redacted] មន្នី** ថា៖ សូមធ្វើសេចក្តីសន្និដ្ឋានការពារផ្អែកលើអង្គហេតុ និងអង្គច្បាប់ដូចតទៅ៖

<u>ក. អង្គហេតុ</u>

ក.១ ជនត្រូវចោទឈ្មោះ [redacted] គីមហ្សូរ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១:៣០នាទីរសៀល ឈ្មោះ [redacted] គីមហ្សូរ បានជិះម៉ូតូរបស់ខ្លួនទៅមើលចំការ ដែលនៅឆ្ងាយពីផ្ទះរបស់ខ្លួនប្រមាណ១០០០ម៉ែត្រ ស្ថិតនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ រហូតដល់ម៉ោងប្រហែល១:៤៥នាទី



Scanned with CamScanner

រសៀល ឈ្មោះ [redacted]គីមហ្សូរ បានជិះម៉ូតូជិះមកដល់ចំណុចជិតស្នាក់ការភូមិអញ្ចាញ ក៏បានឃើញប្រជាពលរដ្ឋនៅជួបជុំគ្នាប្រហែល ២០០នាក់ ពេលឃើញប្រជាពលរដ្ឋនៅជុំគ្នាច្រើន ខ្លួនធ្លាប់ក៏បានចុះពីលើម៉ូតូដើរទៅមើលឃើញថាក្រុមការងាររបស់អាជ្ញាធរអប្សរាចំនួនពីរឡាន ម៉ូតូប្រហែល៥ទៅ៦គ្រឿង បានចុះមករុះរើផ្ទះរបស់ប្រជាពលរដ្ឋ ហើយត្រូវបានប្រជាពលរដ្ឋហាមឃាត់នៅទីនោះហាមឃាត់មិនឲ្យធ្វើការរុះរើទេ សកម្មភាពដែលប្រជាពលរដ្ឋធ្វើការហាមឃាត់អាជ្ញាធរមិនឲ្យធ្វើការរុះរើឈ្មោះ [redacted] គីមហ្សូរ មើលមិនច្បាស់ទេ ដោយសារខ្លួនឈរមើលពីចម្ងាយហើយពលរដ្ឋដែលបានចូលទៅរាំងអាជ្ញាធរគឺមានចំនួនច្រើន ដូចនេះខ្លួនមិនបានចាំថាជាអ្នកណាខ្លះទេ។ ការហាមឃាត់របស់ពលរដ្ឋគឺធ្វើឲ្យអាជ្ញាធរអប្សរាមិនអាចធ្វើការរុះរើបាន ទើបឃើញក្រុមការងារបើកឡានត្រលប់ទៅវិញ នៅម៉ោងប្រហែល២:០០នាទីរសៀល។ នៅពេលដែលក្រុមការងារជាតិអប្សរាបើកឡានត្រលប់មកផ្ទះវិញគឺមានប្រជាពលរដ្ឋជាច្រើនបានជិះម៉ូតូតាមពីក្រោយ ហើយពេលនោះខ្លួនក៏បានជិះម៉ូតូតាមក្រោយដើម្បីគោលដៅធ្វើដំណើរទៅផ្ទះរបស់ខ្លួនដែលស្របផ្លូវគ្នានោះ។ ចំពោះសកម្មភាពដែលថាមានការរើសដុំថ្មគប់ មានការយកដំបងវាយ និងគប់ស្បែកជើងទៅលើក្រុមការងារគឺខ្លួនពុំបានឃើញទេ។

ក.២ ជនត្រូវចោទឈ្មោះ [redacted]ផល្លា នៅថ្ងៃកើតហេតុថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ឈ្មោះ[redacted]ផល្លា បានអង្គុយនៅមុខផ្ទះរបស់ឈ្មោះ [redacted] សេរ ដែលជាមន្ត្រីនគរបាលនៅប៉ុស្តិ៍រដ្ឋបាលនគរធំ ដែលមានទីតាំងស្ថិតនៅជាប់ស្នាក់ការភូមិមានទីតាំង ប្រហែល១០០០ម៉ែត្រពីទីតាំងកើតហេតុ។ នៅពេលដែលកំពុងអង្គុយនៅផ្ទះរបស់ឈ្មោះ [redacted] សេរ ក៏បានលឺតាមរយៈអាយកូមរបស់ឈ្មោះ [redacted] សេរ រាយការណ៍ថាមានក្រុមការងារអាជ្ញាធរអប្សរា ចុះមករុះរើផ្ទះរបស់ប្រជាពលរដ្ឋនៅតំបន់នោះ ហើយនៅវេលាម៉ោង២ថ្ងៃត្រង់ ឈ្មោះ [redacted] សេរ ក៏បានមកបបួលឈ្មោះ [redacted] ផល្លា ចុះទៅមើលការរុះរើជាមួយគាត់ដើម្បីបានជាគ្នា ក្នុងគោលបំណងហាមឃាត់កុំឲ្យប្រើហិង្សាតែប៉ុណ្ណោះ ហើយឈ្មោះ [redacted]សេរ បានជិះម៉ូតូរបស់គាត់ឌុបឈ្មោះ យី ផល្លា ចុះទៅទីតាំងកន្លែងកើតហេតុនៅជិតសាលាឆទានអញ្ចាញ។ នៅពេលដែលឈ្មោះ [redacted] សេរ ចុះទៅដល់ដោយសារមានមនុស្សច្រើនពេកមិនអាចធ្វើដំណើរទៅមុខបានឈ្មោះ [redacted] សេរ ក៏បណ្តើរម៉ូតូទៅមុខយឺតៗ ហេតុនេះឈ្មោះ[redacted] ផល្លា បានចុះដើរបន្តិចដោយស្ថិតនៅជាប់នឹងឈ្មោះ [redacted] សេរ មិនបានការឃ្លាតគ្នានោះទេ ដែលគេរៀបចំត្រៀមបំបែកគ្នាហើយ ពេលនោះក៏ឃើញឡានអាជ្ញាធរអប្សរាពីរបីឡានបើកចេញមកវិញ ហើយប្រជាពលរដ្ឋក៏បានបំបែកគ្នាអស់បណ្តើរៗហើយដែរ។ នៅពេលដែលដើរចេញផុតពីហ្វូងមនុស្សបន្តិចហើយឈ្មោះ[redacted]ផល្លា បានឡើងជិះម៉ូតូជាមួយឈ្មោះ[redacted] សេរ ហើយបន្តដំណើរមកកាន់ផ្ទះរបស់ឈ្មោះ [redacted] សេរ វិញរួចហើយក៏បំបែកគ្នា។

ខ. អង្គច្បាប់ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា២៤. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ "បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។" មាត្រា៥០៦. បទប្រឆាំងនឹងការអនុវត្តការងារសាធារណៈ: "អំពើប្រឆាំងដោយហិង្សាទៅលើការអនុវត្តការងារសាធារណៈ ឬការងារដែលមានប្រយោជន៍ជាសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ១(មួយ)ខែ ទៅ៣(បី)ខែ និងពិន័យជាប្រាក់ពី១០០.០០០(មួយសែន) រៀល ទៅ៥០០.០០០(ប្រាំសែន)រៀល។" មាត្រា ២១៧. បទហិង្សាដោយចេតនា "អំពើហិង្សាប្រព្រឹត្តដោយចេតនាលើអ្នកដទៃត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ៦.០០០.០០០(ប្រាំមួយលាន)រៀល។" មាត្រា ២៣៤. បទគំរាមកំហែងថានឹងសម្លាប់



Scanned with CamScanner

ដោយមានបញ្ញាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ “ការគំរាមកំហែងថានឹងសម្លាប់ក្រោមទម្រង់ណាក៏ដោយ ប្រសិនបើការគំរាមកំហែងនេះត្រូវបានធ្វើឡើងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ៦.០០០.០០០(ប្រាំមួយលាន)រៀល។”

អវត្តមាននធាតុផ្សំបទល្មើស ជនជាប់ចោទឈ្មោះ [redacted] គីមហួរ ១.ក្នុងសំណុំរឿងខាងលើនេះ កូនក្តីយើងខ្ញុំពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តុលាការ និងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដោយហេតុថានៅថ្ងៃកើតហេតុកូនក្តីយើងខ្ញុំពុំបានចូលរួមប្រព្រឹត្តបទល្មើស ឬ សកម្មភាពខុសច្បាប់នានានោះទេ។ នាថ្ងៃដែលកើតហេតុគឺកូនក្តីខ្ញុំបាទទើបចេញមកពីចំការ ដែលមានវត្តមាននៅជិតទីតាំងរុះរើផ្ទះ ហើយពេលដែលចេញពីចំការមកវិញ ក៏ឃើញមានមនុស្សម្នាជុំៗគ្នា ហើយក៏បានឈប់មើលតែម្តង។ នៅពេលដែលមនុស្សម្នាជុំគ្នានោះ ក៏កូនក្តីយើងខ្ញុំបានដកទូរស័ព្ទមកថត ដោយហេតុថាឃើញមនុស្សម្នាច្រើនមិនដឹងថាគេធ្វើអ្វី តែថតបានតែបន្តិចក៏កូនក្តីយើងខ្ញុំបានដកទូរស័ព្ទឈប់ថតទុកវិញ នៅថ្ងៃកើតហេតុនោះកូនក្តីយើងខ្ញុំពុំបានប្រព្រឹត្តបទល្មើសនោះទេ គឺគ្រាន់តែទៅឈរមើល និងថតសកម្មភាពប្រជាពលរដ្ឋតែប៉ុណ្ណោះ ហើយក៏មិនបានស្រែកឱ្យប្រជាពលរដ្ឋនៅទីនោះចាប់ចងក្រុមការងារអាជ្ញាធរជាតិអប្សរា និងនិយាយថាសម្លាប់ដែរ។ នៅក្នុងសំណុំរឿងខាងលើពុំមានភស្តុតាងណាមួយទាល់តែសោះក្នុងការចោទប្រកាន់មកលើកូនក្តីយើងខ្ញុំ ពោលគឺពុំមានភស្តុតាងជាឯកសារ ឬវីដេអូ ឬសាក្សីទាល់តែសោះ ក្នុងការចោទប្រកាន់មកលើកូនក្តីយើងខ្ញុំ ដោយការចោទប្រកាន់នេះ សំអាងតែលើសំដីរបស់ភាគីជាដើមបណ្តឹង ដោយគ្មានភស្តុតាងជាក់លាក់បញ្ជាក់ថា កូនក្តីយើងខ្ញុំបានប្រើប្រាស់អំពើហិង្សាទៅលើបុគ្គលណាមួយ ឬទៅលើអជ្ញាធរ ឬបុគ្គលណាម្នាក់ ដែលទទួលរងនូវព្យសនកម្មនៃទង្វើរបស់កូនក្តីយើងខ្ញុំ ដែលឈានដល់ការចោទប្រកាន់ ស្របតាមធាតុផ្សំនៃបទនៃមាត្រា២១៧នោះទេ លើសពីនេះដើមបណ្តឹង និងតំណាងអយ្យការក៏មិនបានបង្ហាញនូវភស្តុតាងជាក់លាក់ណាមួយថាកូនក្តីយើងខ្ញុំ បានធ្វើសកម្មភាពប្រើអំពើហិង្សា ឬការបញ្ជារ ឬការចូលរួមក្នុងការប្រើអំពើអំពើហិង្សានេះផងដែរ។ កូនក្តីយើងខ្ញុំឈ្មោះ [redacted] គីមហួរ ត្បិតតែមានវត្តមាននៅទៅនោះពិតមែន ប៉ុន្តែមិនមាននូវសកម្មភាពណាមួយទាល់តែសោះក្នុងការប្រព្រឹត្តបទល្មើសនេះ។ ហេតុដូច្នេះពុំមាននូវធាតុផ្សំបទល្មើសទាល់តែសោះទាំងធាតុផ្សំអត្តនោម័ត និងធាតុផ្សំសត្យានុម័ត ក្នុងការចោទប្រកាន់មកលើកូនក្តីយើងខ្ញុំ ពីបទល្មើសបទប្រឆាំងនឹងការអនុវត្តការងារសាធារណៈ ស្របតាមមាត្រា ៥០៦ ដែលសកម្មភាពរបស់កូនក្តីយើងខ្ញុំមិនបានទៅរាំងការអនុវត្តរបស់អាជ្ញាធរ ឬបានទៅស្រែកតវ៉ា ឬទៅឈរពាំងដោយមានកាន់សម្ភារៈគ្រោះថ្នាក់ណាមួយ ហាមឃាត់អាជ្ញាធរមិនឱ្យធ្វើការរុះរើនោះទេ ព្រោះការរុះរើនេះ គឺមិនមែនមកធ្វើការរុះរើផ្ទះរបស់កូនក្តីយើងខ្ញុំនោះដែរ លើសពីនេះកូនក្តីយើងខ្ញុំក៏មិនបានទៅហាមឃាត់អាជ្ញាធរណាមួយមិនឱ្យធ្វើការរុះរើផងដែរ ដោយគាត់មិនបានកាន់នូវវត្ថុណាមួយដែលបានគម្រាមកំហែង ឬការចូលរួមទៅហាមឃាត់មិនឱ្យគេចូលទៅរុះរើនោះទេ។ ចំពោះការចោទប្រកាន់កូនក្តីយើងខ្ញុំថាគំរាមកំហែងថានឹងសម្លាប់ ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយនោះ រឹងតែមិនមាននូវធាតុផ្សំបទល្មើសគ្រប់គ្រាន់ទៅទៀត ព្រោះកូនក្តីយើងខ្ញុំមិនបានទាំងនិយាយស្តីមួយម៉ាត់ជាមួយនឹងអាជ្ញាធរផង តើមានវីដេអូ ឬភស្តុតាងអ្វីដែលថាកូនក្តីយើងខ្ញុំទៅស្រែក ឬទៅនិយាយគម្រាមថានឹងសម្លាប់អ្នកណាម្នាក់នោះ ការចោទប្រកាន់នេះគឺមិនបានពិនិត្យទៅលើអង្គហេតុ និងអង្គច្បាប់ឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយការចោទប្រកាន់មិនត្រឹមត្រូវព្រោះខ្វះធាតុផ្សំនៃបទល្មើស លើសពីនេះពឹងតែចម្លើយរបស់ដើមបណ្តឹងតែម្នាក់ឯង ឈ្មោះ



Scanned with CamScanner

[redacted] ជរ ដែលទើបតែធ្វើការអះអាងនៅដំណាក់កាលជំនុំជម្រះនេះ ដោយធ្វើការចោទប្រកាន់មកលើកូនក្តីខ្ញុំបាទនោះ គឺរឹតតែមិនពិតប្រាកដទៅទៀតហើយ ព្រោះនេះជាសម្តីតែម្ខាងរបស់ឈ្មោះ [redacted] ជរ ហើយកូនក្តីយើងខ្ញុំអះអាងហើយថាមិនបានប្រព្រឹត្តសកម្មភាពដូច្នេះទេ។ មួយវិញទៀតសាក្សីឈ្មោះ [redacted] ទៀង ដែលឈរនៅជិតកូនក្តីយើងខ្ញុំបានអះអាងយ៉ាងច្បាស់ថាខ្លួនស្គាល់ឈ្មោះ [redacted] ជរ យ៉ាងច្បាស់ ហើយឈ្មោះ [redacted] ជរ ក៏អះអាងថាស្គាល់ឈ្មោះ [redacted] ទៀងច្បាស់ផងដែរ ហេតុអ្វីនៅពេលនោះ ដែលឈ្មោះ [redacted] ទៀង នៅជិតកូនក្តីយើងខ្ញុំ តែមិនបានឃើញឈ្មោះ [redacted] ជរ នៅឈរក្បែរនោះ នេះសបញ្ជាក់ឱ្យឃើញថាការអះអាងរបស់ឈ្មោះ [redacted] ជរ ជាការអះអាងមិនពិតប្រាកដនោះទេ ព្រោះមានតែខ្លួនឯងម្នាក់ដែលដឹង អ្នកផ្សេងទៀតមិនបានដឹងរឿងនឹងនោះទេ ដូចបានរៀបរាប់ខាងលើ តុលាការពុំអាចចោទប្រកាន់កូនក្តីយើងខ្ញុំពីបទល្មើស ដែលកូនក្តីយើងខ្ញុំពុំបានប្រព្រឹត្ត ពោលគឺផ្ទុយនឹងគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌមាត្រា ២៤ ។ ហេតុនេះការចោទប្រកាន់របស់តុលាការមកលើកូនក្តីយើងខ្ញុំឈ្មោះ [redacted] គឹមសួរ អំពីបទល្មើស ប្រឆាំងនឹងការអនុវត្តការងារសាធារណៈ, ហិង្សាដោយចេតនា, គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឲ្យបំពេញលក្ខណ្ឌអ្វីមួយគឺមិនមានភាពត្រឹមត្រូវ និងពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់នោះទេ ព្រោះកូនក្តីយើងខ្ញុំមិនមានការពាក់ព័ន្ធចំពោះបទល្មើសខាងលើទាល់តែសោះ។ ដូច្នេះការចោទប្រកាន់របស់តុលាការគឺមានសភាពធ្ងន់ធ្ងរជាខ្លាំងមកលើកូនក្តីយើងខ្ញុំដែលជាប្រជាពលរដ្ឋស្លូតត្រង់។ ហេតុនេះតុលាការគប្បីពិចារណាដល់ស្ថានភាពអង្គហេតុ និងអង្គច្បាប់ដែលបានកើតឡើងឱ្យបានស៊ីជម្រៅ និងផ្តល់នូវសេចក្តីយុត្តិធម៌ដល់កូនក្តីយើងខ្ញុំឈ្មោះ [redacted] គឹមហួរ តាមផ្លូវច្បាប់មកវិញផង។

ជនជាប់ចោទឈ្មោះ [redacted] ផល្លា នៅក្នុងសំណុំរឿងខាងលើនេះ ការចោទប្រកាន់ពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី និងតុលាការ មកលើកូនក្តីយើងខ្ញុំឈ្មោះ [redacted] ផល្លា គឺពុំមានភាពត្រឹមត្រូវទាល់តែសោះ។ នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ គឺកូនក្តីយើងខ្ញុំពុំមានសកម្មភាពណាមួយនៅទីតាំងកើតហេតុនោះទេ។ ភស្តុតាងដែលដាក់បន្ទុកមកលើកូនក្តីយើងគឺរូបថតមួយសន្លឹករបស់ឈ្មោះ [redacted] ផល្លា មានវត្តមាននៅផ្ទះរបស់ឈ្មោះ [redacted] សេរ ជាមន្ត្រីនគរបាលដែលផ្ទះនោះជាប់នឹងស្នាក់ការភូមិ ហើយមានទីតាំងឆ្ងាយពីទីតាំងកើតហេតុ១០០០ម៉ែត្រឯណោះ។ ចម្ងល់នៅត្រង់ចំណុចនេះ ថាតើឈ្មោះ [redacted] ផល្លា អាចទៅប្រព្រឹត្តបទល្មើសឯណាបាន ក្នុងករណីដែលកូនក្តីយើងខ្ញុំមិនបានជាប់ពាក់ព័ន្ធអ្វីទាល់តែសោះនៅក្នុងដំណើររឿងនេះ? ទី១ ការរុះរើមិនមែនធ្វើការរុះរើផ្ទះរបស់កូនក្តីយើងខ្ញុំនោះទេ។ ទី២ ការដែលកូនក្តីយើងខ្ញុំទៅនេះ គឺដោយសារឈ្មោះ [redacted] សេរ ដែលជាមន្ត្រីនគរបាលជាអ្នកហៅទៅបានជាគ្នាប៉ុណ្ណោះ។ ទី៣ កូនក្តីយើងខ្ញុំទៅដល់គឺខាងអាជ្ញាធរ និងប្រជាពលរដ្ឋបានបំបែកគ្នាហើយ ដោយគាត់ទៅគឺនៅសល់តែប្រជាពលរដ្ឋនៅជុំគ្នាចុងក្រោយប៉ុណ្ណោះ។ ទី៤. សកម្មភាពនៅក្នុងហេតុការរារាំង សកម្មភាពក្នុងហេតុការដេញវាយ និងសកម្មភាពក្នុងហេតុការឈ្លោះប្រកែកគ្នានោះ គឺកូនក្តីយើងខ្ញុំមិនបានទៅទាន់មិនបានចូលរួមនឹងមិនបានដឹងច្បាស់ថែមទៀត។ ហេតុនេះតើអាចទៅប្រព្រឹត្តបទល្មើសម្តេចនឹងបាន? ព្រោះពេលកើតហេតុកូនក្តី យើងខ្ញុំមានវត្តមានឆ្ងាយពីទីតាំងកើតហេតុរហូតដល់ ១០០០ម៉ែត្រ។ កូនក្តីយើងខ្ញុំដឹងអំពីករណីរុះរើនេះ គឺដោយសារតែអាជ្ញាធរអប្បរាស្នើសុំការសហការពីស្នាក់ការភូមិ ដែលលឺចេញពីអាយកូមរបស់ឈ្មោះ [redacted] សេរ ហើយឈ្មោះ [redacted] សេរជាអ្នកហៅកូនក្តីយើងខ្ញុំទៅជាមួយថែមទៀតបានជាគ្នាប៉ុណ្ណោះ។ យើងខ្ញុំសូមបញ្ជាក់ថា ការចោទប្រកាន់មកលើកូនក្តីយើងខ្ញុំនេះគឺពិតជាមិនត្រឹមត្រូវនោះទេ ព្រោះថាការចោទប្រកាន់ថាកូនក្តីយើងខ្ញុំធ្វើការប្រឆាំងនឹងការអនុវត្ត



Scanned with CamScanner

ការងារសាធារណៈនោះគឺមិនមានធាតុផ្សំនៃបទល្មើសណាមួយទាន់តែសោះ ដោយសារពេលកំពុងកើតហេតុនៃការរារាំងនោះ គឺកូនក្តីយើងខ្ញុំមិនបានស្ថិតនៅកន្លែងកើតហេតុនោះទេ កូនក្តីយើងខ្ញុំទៅតាមក្រោយដោយឈ្មោះ [redacted] សេរជាអ្នកដឹកទៅដោយកូនក្តីយើងខ្ញុំទៅដល់អាជ្ញាធរនឹងប្រជាពលរដ្ឋបានបំបែកគ្នាហើយ នៅជុំតែប្រជាពលរដ្ឋនោះទេ ហេតុនេះកូនក្តីយើងខ្ញុំមិនបានទាំងដឹងថាគេបានធ្វើអ្វីខ្លះផង បែរជាមកចោទប្រកាន់កូនក្តីយើងខ្ញុំដូច្នេះទៅវិញ សួរថាតើកូនក្តីយើងខ្ញុំទៅធ្វើការរារាំងដល់អាជ្ញាមិនឱ្យអនុវត្តយ៉ាងណាទៅ។ ចំពោះការចោទប្រកាន់អំពីបទហិង្សាដោយចេតនានោះរឹតតែមិនមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ទៅទៀត ព្រោះយោងតាមភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង នឹងការអះអាងទាំងនោះ គឺកូនក្តីយើងខ្ញុំមិនបានទៅប្រើហិង្សាលើបុគ្គលណាមួយ ឬធ្វើការជិះជាន់ឬវាយ ឬគប់លើបុគ្គលណាមួយ ឬបុគ្គលណាមួយទទួលរងព្យុះសនកម្មពីសកម្មភាពរបស់កូនក្តីយើងខ្ញុំជារបួសស្នាមនោះទេ ហេតុនេះការចោទប្រកាន់លើការប្រើប្រាស់ហិង្សានេះគឺមានរូបភាពផ្ទុយពីបទល្មើសទាំងស្រុង លើសពីនេះដើមបណ្តឹង និងតំណាងអយ្យការក៏មិនបានបង្ហាញនូវភស្តុតាងជាក់លាក់ណាមួយថាកូនក្តីយើងខ្ញុំបានធ្វើសកម្មភាពប្រើអំពើហិង្សា ឬការបញ្ជារ ឬការចូលរួមក្នុងការប្រើអំពើអំពើហិង្សានេះផងដែរ។ រីឯការចោទប្រកាន់ថាកូនក្តីយើងខ្ញុំគំរាមកំហែងថានឹងសម្លាប់ ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយនោះ រឹងតែមិនមាននូវធាតុផ្សំបទល្មើសគ្រប់គ្រាន់ទៅទៀត ព្រោះថាការចោទប្រកាន់នេះគឺមានតែចម្លើយរបស់អ្នកប្តឹងតែម្នាក់គត់ឈ្មោះ [redacted] ជរ ដែលបានធ្វើការអះអាងតែផ្ទុយពីការពិតទាំងស្រុង ព្រោះថាកូនក្តីយើងខ្ញុំទៅដល់គឺអាជ្ញាធរបានបំបែកគ្នាជាមួយប្រជាពលរដ្ឋហើយ ហើយឡានអាជ្ញាធរនៅឆ្ងាយពីកូនក្តីយើងខ្ញុំថែមទៀត លើសពីនេះគ្មានអ្នកណាម្នាក់បានលឺរួមទាំងអ្នកដែលបានដុបកូនក្តីយើងខ្ញុំទៅឈ្មោះ [redacted] សេរ ដោយឈ្មោះ [redacted] សេរ បានបញ្ជាក់ហើយថា មិនឃើញអ្នកណាស្រែកអ្វីទេ ជាពិសេសគឺកូនក្តីយើងខ្ញុំដែលនៅក្បែរខ្លួនគាត់ ក៏មិនបានលឺការស្រែពីកូនក្តីយើងខ្ញុំដែរ ហេតុអ្វីឈ្មោះ [redacted] ជរ ដែលនៅឆ្ងាយនោះ បានស្តាប់លឺទាំងមានមនុស្សជាច្រើននៅជុំវិញនោះថែមទៀត។ ការអះអាងរបស់ឈ្មោះ [redacted] ជរ ដែលថាខ្លួនឈរនៅទល់មុខកូនក្តីយើងខ្ញុំនោះរឹតតែមិនពិតប្រាកដទៅទៀត ព្រោះថាតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សេរ គឺបញ្ជាក់ហើយថាបានស្គាល់ឈ្មោះ [redacted] ជរ នេះយ៉ាងច្បាស់ ហើយឈ្មោះ [redacted] ជរ ក៏បានបញ្ជាក់ហើយថាបានស្គាល់ឈ្មោះ [redacted] សេរ យ៉ាងច្បាស់ ហេតុអ្វីនៅពេលនោះឈ្មោះ [redacted] សេរ បានអះអាងហើយថាមិនបានឃើញ ឈ្មោះ [redacted] ជរ ទាំងដែលកូនក្តីយើងខ្ញុំឈរនៅក្បែរឈ្មោះ [redacted] សេរ មិនបានដើរទៅណាមួយជិហាននោះទេ នេះបញ្ជាក់ឱ្យឃើញថាការអះអាងរបស់ឈ្មោះ [redacted] ជរ ដែលបានអះអាងតែម្នាក់ឯងមិនមានការពិតនោះទេ។ជាការពិតកូនក្តីយើងខ្ញុំមិនដែលទៅបានដឹងរឿងអ្វីនោះទេ ដោយគាត់រស់នៅស្រុកភូមិនោះជាធម្មតា ហើយថ្ងៃកើតហេតុគាត់ទៅលេងផ្ទះឈ្មោះ [redacted] សេរ ជាធម្មតាក្រោយបាយហើយដោយសារនៅផ្ទះក្បែរគ្នាប៉ុណ្ណោះ។ ហេតុនេះគ្មានមូលហេតុអ្វី និងភស្តុតាងណាមួយបញ្ជាក់ជាក់លាក់ដែលបានធ្វើការចោទប្រកាន់មកលើកូនក្តីយើងខ្ញុំនោះទេ។ យើងខ្ញុំសូមបញ្ជាក់ថាសកម្មភាពដែលកូនក្តីយើងខ្ញុំ ចេញទៅកន្លែងកើតហេតុ គឺទៅជាមួយឈ្មោះ [redacted] សេរ ជាមន្ត្រីនគរបាលក្នុងគោលបំណងទៅឱ្យបានគ្នា ដោយឈ្មោះ [redacted] សេរ ចង់ទៅហាមឃាត់កុំឱ្យមានអំពើហិង្សាតែប៉ុណ្ណោះ។ ហើយឈ្មោះ សុទ្ធ នៅក្បែរកូនក្តីយើងខ្ញុំរហូតពីដើមដល់ចប់ ដោយបានអះអាងបញ្ជាក់ថាមិនបានឃើញឈ្មោះ [redacted] ជរ នៅក្បែរនោះ រឹតតែមិនបានឃើញកូនក្តីយើងខ្ញុំស្រែគម្រាមថាសម្លាប់អ្នកណាម្នាក់នោះទេ ជាពិសេសទៅលើឈ្មោះ [redacted] ជរ នេះតែម្តង។ លើសពីនេះនៅពេលដែលកូនក្តីយើងខ្ញុំ បានទៅដល់ទីតាំង កើតហេតុ



Scanned with CamScanner

នោះគឺពុំមានអំពើហិង្សាកើតឡើងនោះទេ ហើយគឺអាជ្ញាធរអប្សរ និងប្រជនពលរដ្ឋបានបំបែកគ្នាអស់ ហើយ ពុំមានការប្រទូស្តរាយទាល់តែសោះ។ តុលាការពុំអាចចោទប្រកាន់កូនក្តីយើងខ្ញុំពីបទល្មើសដែលកូនក្តីយើងខ្ញុំពុំបានប្រព្រឹត្តពោលគឺផ្ទុយនឹងគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌមាត្រា២៤។ ហេតុនេះការចោទប្រកាន់របស់តុលាការមកលើកូនក្តីយើងខ្ញុំអំពីបទល្មើស ប្រឆាំងនឹងការអនុវត្តការងារសាធារណៈ, ហិង្សាដោយចេតនា, គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខណ្ឌអ្វីមួយ គឺមិនមានភាពត្រឹមត្រូវ និងពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់នោះទេ ព្រោះកូនក្តីយើងខ្ញុំមិនមានការពាក់ព័ន្ធចំពោះបទល្មើសខាងលើដែរ។ ដូច្នេះការចោទប្រកាន់របស់តុលាការគឺមានសភាពធ្ងន់ធ្ងរជាខ្លាំងមកលើកូនក្តី យើងខ្ញុំដែលជាប្រជាពលរដ្ឋស្លូតត្រង់។ ហេតុនេះតុលាការគប្បីពិចារណាដល់ស្ថានភាព អង្គហេតុ និងអង្គច្បាប់ ដែលបានកើតឡើងឱ្យបានស៊ីជម្រៅ និងផ្តល់ នូវសេចក្តីយុត្តិធម៌ដល់កូនក្តីយើងខ្ញុំតាមផ្លូវច្បាប់។

គ. សន្និដ្ឋាន យោងតាមអង្គហេតុ អង្គច្បាប់ និងភស្តុតាងដូចបានរៀបរាប់ខាងលើ យើងអាចសន្និដ្ឋានបានថាការចោទប្រកាន់របស់តុលាការមកលើកូនក្តីយើងខ្ញុំឈ្មោះ [redacted] គីមហួរ និងឈ្មោះ [redacted] ផល្លា គឺមានសភាពធ្ងន់ធ្ងរជាខ្លាំង និងមិនមានភស្តុតាងដាក់បន្ទុកច្បាស់លាស់មកលើកូនក្តីយើងខ្ញុំ ថាបានប្រព្រឹត្តសកម្មភាពណាមួយដោយផ្អែកលើភស្តុតាងណាមួយជាក់លាក់ ដោយពោពេញទៅដោយវិមតិសង្ស័យ និងហេតុមិនជាក់លាក់ពិតប្រាកដ ទាំងអស់ ដោយមិនបានបង្ហាញអំពីសកម្មភាព ឬទង្វើរបស់កូនក្តីយើងខ្ញុំអំពីការរារាំងបែបណា ការប្រើអំពើហិង្សា បែបណា ឬការគម្រាមថានឹងសម្លាប់បែបណា ដែលអាចកំណត់បានថាជាបទល្មើសនោះទេ ដែលគប្បីឱ្យតុលាការពិចារណាដើម្បីផ្តល់នូវសេចក្តីយុត្តិធម៌ដល់កូនក្តីយើងខ្ញុំ។

ឃ. សំណូមពរ តាមរយៈអង្គហេតុអង្គច្បាប់ និងភស្តុតាងដែលបានរៀបរាប់ខាងលើ ក្នុងនាមយើងខ្ញុំជាមេធាវីការពារសិទ្ធិរបស់ជនត្រូវចោទឈ្មោះ [redacted] គីមហួរ និងឈ្មោះ [redacted] ផល្លា យើងខ្ញុំធ្វើការសំណូមពរដល់តុលាការពិចារណា និងសម្រេចឱ្យកូនក្តីឈ្មោះ [redacted] គីមហួរ និងឈ្មោះ [redacted] ផល្លា រួចផុតពីបទចោទពីបទ ប្រឆាំងនឹងការអនុវត្តការងារសាធារណៈ ហិង្សាដោយចេតនា គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជារឱ្យបំពេញលក្ខណ្ឌអ្វីមួយ។

(១៨)-តាមចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់ ចម្លើយរបស់តំណាងដើមបណ្តឹង ចម្លើយរបស់ជនរងគ្រោះការបំភ្លឺរបស់សាក្សី និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង តុលាការជឿបានថា ជនជាប់ចោទទាំងពីរនាក់មានឈ្មោះ [redacted] ផល្លា និងឈ្មោះ [redacted] គីមហួរ ពិតជាបានប្រព្រឹត្តអំពើ "ប្រឆាំងនឹងការអនុវត្តការងារសាធារណៈ និងគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ" តែមិនមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទទាំងពីរនាក់ក្នុងអង្គហេតុនៃអំពើហិង្សាដោយចេតនានោះឡើយ។ ការឆ្លើយបដិសេធរបស់ជនជាប់ចោទថាពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ចម្លើយបដិសេធរបស់ជនជាប់ចោទគ្រាន់តែជាការឆ្លើយគេចវេសពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនតែប៉ុណ្ណោះ។

(១៩)- អំពើរបស់ជនជាប់ចោទទាំង០២នាក់ខាងលើ បានឆ្លើយតបគ្រប់គ្រាន់នូវធាតុផ្សំនៃបទ "ប្រឆាំងនឹងការអនុវត្តការងារសាធារណៈ និងគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ" បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥០៦ និងមាត្រា២៣៤ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

(២០)- មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទទាំង០២នាក់ដែលមានឈ្មោះ [redacted] ផល្លា និងឈ្មោះ [redacted] គីមហ្វួរ ពីបទ "ប្រឆាំងនឹងការអនុវត្តការងារសាធារណៈ និងគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ" ប្រព្រឹត្តនៅចំណុចភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥០៦ និងមាត្រា២៣៤ នៃក្រមព្រហ្មទណ្ឌ។

(២១)- ការប្រកាសទោស

- ជនជាប់ចោទឈ្មោះទាំង០២នាក់ ខាងលើដែលមានឈ្មោះ [redacted] ផល្លា និងឈ្មោះ [redacted] គីមហ្វួរ ជានីតិជនមានបុគ្គលិកលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌបាន។ ជនជាប់ចោទមានសមត្ថភាពខាងឆន្ទៈ ឬមានស្មារតីទទួលស្គាល់ថាអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលកើតចេញពីអំពើដែលខ្លួនប្រព្រឹត្ត។

- គប្បីពិចារណាលើរបបនៃការប្រកាសទោសដោយឱ្យមានការព្យួរទោសធម្មតាទាំងមូលដល់ជនជាប់ចោទទាំងពីរ ដោយពិនិត្យឃើញនូវស្ថានភាពផ្សេងៗដែលពាក់ព័ន្ធនឹងលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

  - ជនជាប់ចោទទាំងពីរនាក់នេះ មិនត្រូវបានអយ្យការឃាត់ខ្លួន ហើយចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួន ជនជាប់ចោទបានរស់នៅក្នុងសង្គមដោយមិនឃើញមានអំពើអសកម្មណាមួយកើតឡើងឡើយ។
  - ជនជាប់ចោទពុំមានប្រវត្តិនៃការផ្តន្ទាទោសពីមុនមក កំហុសនេះជាកំហុសលើកទី១របស់ខ្លួន។ ស្ថានភាពនេះ គប្បីតុលាការទុកឱកាសអោយជនជាប់ចោទ ដែលប្រព្រឹត្តខុសមានឱកាសបានកែប្រែខ្លួនឡើងវិញ។

(២២)- អាជ្ញាធរជាតិអប្សរាតំណាងដោយលោក [redacted] ពៅ ជាដើមបណ្តឹងរដ្ឋប្បវេណី បានទាមទារសំណងសំណងរដ្ឋប្បវេណីលើជនជាប់ចោទទាំងពីរនាក់ និងបក្សពួក ជាប្រាក់សរុបចំនួន ១០០,០០០,០០០៛ (មួយរយលាន) រៀល។ ឃើញថា ការទាមទារសំណងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនច្រើន គប្បីតុលាការលើកមកពិចារណាអោយបានសមរម្យតាមទំហំព្យសនកម្ម និងកម្រិតជីវភាពរបស់ជនជាប់ចោទទាំងពីរនាក់។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទដែលមានអត្តសញ្ញាណដូចខាងក្រោម៖

**ក.** ឈ្មោះ [redacted] **ផល្លា** ភេទប្រុស អាយុ៥៤ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិតាប៉ោង ឃុំសំឡី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៧ មុខរបរមន្ត្រីចូលនិវត្តន៍ ឪពុកឈ្មោះ [redacted] ឈួន (ស) ម្តាយឈ្មោះ [redacted] គីន (រ) ប្រពន្ធឈ្មោះ [redacted] ភារី មានកូន៣នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។ (ក្រៅឃុំ)

**ខ.** ឈ្មោះ [redacted] **គីមហ្វួរ** ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិភ្នំជញ្ជាំង ឃុំជប់វារី ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ននៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៥ មុខរបរកសិករ ឪពុកឈ្មោះ [redacted] ហាក់ (រ) ម្តាយឈ្មោះ [redacted] អឿន (រ) ប្រពន្ធឈ្មោះ [redacted] គីមឃឿន មានកូន៣នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយ តុលាការគ្មាន។ (ក្រៅឃុំ)

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០១(មួយ)ឆ្នាំ តែទោសនេះត្រូវអនុវត្តព្យួរធម្មតា។



Scanned with CamScanner

ពីបទ "ប្រឆាំងនឹងការអនុវត្តការងារសាធារណៈ និងគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ" ប្រព្រឹត្តនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥០៦ និងមាត្រា២៣៤នៃក្រមព្រហ្មទណ្ឌ។

២ - ឱ្យឈ្មោះ [redacted] ផល្លា និងឈ្មោះ [redacted] គីមហ្សូរ រួមគ្នាបង់សំណងការខូចខាត និងជម្ងឺចិត្តសរុបជាប្រាក់ចំនួន ៦,០០០,០០០៛ (ប្រាំមួយលាន)រៀល ឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពៅ តំណាងអាជ្ញាធរជាតិអប្សរា បណ្តឹងទាមទារសុំលើសពីនេះបដិសេធចោល។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំងពីរនាក់ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

សៀមរាប, ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពីច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី

សៀមរាប ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner